ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

**<u>ចំណាំ</u>** :
- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការចំណូល ចំណាយឃុំ សង្កាត់ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។
- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

**២០-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស " លេខ ១១២៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស នៅធនាគារអេស៊ីលីដា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

**<u>ចំណាំ</u>** :
- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេស៊ីលីដាសម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។
- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

**២១-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ " លេខ ១១២៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ នៅធនាគារអេស៊ីលីដា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

__ចំណាំ__ :- គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្តនៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិតត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

**២២-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា "លេខ ១១២៥ ":**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នៅធនាគារអេស៊ីលីដា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

__ចំណាំ__ :- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេស៊ីលីដាសម្រាប់ប្រតិបត្តិការធានាការអនុវត្តកិច្ចសន្យា នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិតត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

**២៣-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៣០ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារកាណាឌីយ៉ា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលបានបង្វែរពីធនាគារ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

__ចំណាំ__ :- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារកាណាឌីយ៉ាសម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

**២៤-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការចំណាយ " លេខ ១១៣១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារកាណាឌីយ៉ា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាជាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

**<u>ចំណាំ</u>** :- គណនីនេះត្រូវបែកជាអនុគណនី គណនីចរន្តនៅធនាគារកាណាឌីយ៉ាសម្រាប់ប្រតិបត្តិការចំណាយ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

**២៥-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការចំណូល ចំណាយឃុំ សង្កាត់ " លេខ ១១៣២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃប្រតិបត្តិការចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារកាណាឌីយ៉ា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

**<u>ចំណាំ</u>** :- គណនីនេះត្រូវបែកជាអនុគណនី គណនីចរន្តនៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការចំណូល ចំណាយឃុំ សង្កាត់ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

**២៦-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស " លេខ ១១៣៣ " :**

គណនីនេះប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀលសម្រាប់ប្រតិបត្តិការបៀវត្សនៅធនាគារកាណាឌីយ៉ា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

**<u>ចំណាំ</u>** :- គណនីនេះត្រូវបែកជាអនុគណនី គណនីចរន្តនៅធនាគារកាណាឌីយ៉ាសម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស នៅតាមរាជធានីខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

**២៧-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ " លេខ ១១៣៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃនៅធនាគារកាណាឌីយ៉ា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

**<u>ចំណាំ</u>** :- គណនីនេះត្រូវបែកជាអនុគណនី គណនី ចរន្តនៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិតត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

**២៨-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា "លេខ ១១៣៥ ":**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នៅធនាគារកាណាឌីយ៉ា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

**សមតុល្យ** : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

**ចំណាំ** :- គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិតត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

**២៩-គណនី ចរន្ត នៅធនាគារវឌ្ឍនៈ សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៤០ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារវឌ្ឍនៈ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

**សមតុល្យ** : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារវឌ្ឍនៈ។

**ចំណាំ** :- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារវឌ្ឍនៈ សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារវឌ្ឍនៈ។

**៣០-គណនី ចរន្ត នៅធនាគារឯកទេសវីង សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៥០ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារឯកទេសវីង។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

**សមតុល្យ** : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារឯកទេសវីង។

**ចំណាំ** :- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារឯកទេសវីងសម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារឯកទេសវីង។

**៣១-គណនី ចរន្ត នៅធនាគារអេប៊ីអេ សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៦០ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារអេប៊ីអេ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេប៊ីអេ។

**<u>ចំណាំ</u>** :- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេប៊ីអេ សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេប៊ីអេ។

### ៣២-គណនី ចរន្ត នៅធនាគារកម្ពុជាសាធារណៈ សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៧០ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារកម្ពុជាសាធារណៈ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកម្ពុជាសាធារណៈ។

**<u>ចំណាំ</u>** :- គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្តនៅធនាគារកម្ពុជាសាធារណៈ សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកម្ពុជាសាធារណៈ។

### ៣៣-គណនី ចរន្ត នៅធនាគារអេអិនហ្សេត រ៉ូយ៉ាល់ សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៨០ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារអេអិនហ្សេត រ៉ូយ៉ាល់។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេអិនហ្សេតរ៉ូយ៉ាល់។

**<u>ចំណាំ</u>** :- គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្ត នៅធនាគារអេអិនហ្សេតរ៉ូយ៉ាល់ សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេអិនហ្សេត រ៉ូយ៉ាល់។

### ៣៤-គណនី ប្រាក់បញ្ញើរបស់ថវិកាឧបសម្ព័ន្ធ នៅរតនាគារ " លេខ ១២០១ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់អង្គភាពដែលជាអ្នកអនុវត្តថវិកាឧបសម្ព័ន្ធ ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយថវិកាដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនះវត្ថុ។ គណនីលេខ ១២០១ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកាឧបសម្ព័ន្ធ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនះវត្ថុ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនះវត្ថុ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់អង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ ដែលកំពុងមាននៅរតនាគារ។

**<u>ចំណាំ</u>** : គណនីនេះ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិកាឧបសម្ព័ន្ធ (លេខ ៤៤០១) នៃប្លង់គណនេយ្យរដ្ឋ។

**៣៥-គណនី ប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ “ លេខ ១២០២ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនះវត្ថុ។ គណនីលេខ ១២០២ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការាជធានី ខេត្ត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនះវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទទួលពីរតនាគារ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនះវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានពីរតនាគារដែលបានទូទាត់

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់រាជធានី ខេត្ត ដែលកំពុងមាននៅរតនាគារ។

**<u>ចំណាំ</u>** : គណនីនេះឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត (លេខ ៤៤០២) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។

**៣៦-គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ “ លេខ ១២០៣ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនះវត្ថុ។ គណនីលេខ ១២០៣ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកាក្រុង ស្រុក ខណ្ឌ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនះវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទទួលពីរតនាគារ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនះវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានពីរតនាគារដែលបានទូទាត់

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ ដែលកំពុងមាននៅរតនាគារ។

**<u>ចំណាំ</u>** : គណនីនេះ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។

**៣៧-គណនី ប្រាក់បញ្ញើរបស់ឃុំ សង្កាត់ នៅរតនាគារ “ លេខ ១២០៤ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលឃុំ សង្កាត់ ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយ ដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនះវត្ថុ។ គណនីលេខ ១២០៤ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកាឃុំ សង្កាត់។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនះវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទទួលពីរតនាគារ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនះវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានពីរតនាគារដែលបានទូទាត់

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ឃុំ សង្កាត់ ដែលកំពុងមាននៅរតនាគារ។

**<u>ចំណាំ</u>** : គណនីនេះ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់ឃុំ សង្កាត់ (លេខ ៤៤០៤) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។

**៣៨-គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារ " លេខ ១២០៥ " :**

គណនីនេះប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ។ គណនីលេខ ១២០៥ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

**សមតុល្យ :** ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលកំពុងមាននៅរតនាគារ។

**ចំណាំ** :
- គណនីនេះឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល (លេខ ៤៤០៥) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។
- គណនីនេះត្រូវចែកជាអនុគណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារ ជាប្រាក់រៀល (លេខ ១២០៥១) និងប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ ជាប្រាក់ដុល្លារអាមេរិក (លេខ ១២០៥២)។

**៣៩-គណនី ប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ នៅរតនាគារ " លេខ ១២០៦ " :**

គណនីនេះប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់សហគ្រាសសាធារណៈ ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ។ គណនីលេខ ១២០៦ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការបស់សហគ្រាសសាធារណៈ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

**សមតុល្យ :** ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ ដែលកំពុងមាននៅរតនាគារ។

**ចំណាំ** :
- គណនីនេះឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់សហគ្រាសសាធារណៈ (លេខ ៤៤០៦) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។
- គណនីនេះត្រូវចែកជាអនុគណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច (លេខ ១២០៦១), ប្រាក់បញ្ញើរបស់ក្រុមហ៊ុនរដ្ឋ (លេខ ១២០៦២) និងប្រាក់បញ្ញើរបស់ក្រុមហ៊ុនចំរុះ (លេខ ១២០៦៣)។

**៤០-គណនី ប្រាក់បញ្ញើមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ នៅរតនាគារ " លេខ ១២១១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រានៅក្នុងគណនេយ្យនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិនូវចំនួនទឹកប្រាក់ចំណូល ដែលបានពីថវិការដ្ឋ ដៃគូអភិវឌ្ឍន៍ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ក្រោមក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ និងពីប្រភពផ្សេងទៀត និងកត់ត្រាចំនួនទឹកប្រាក់ចំណាយ ដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការទូទាត់ចំណាយរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

**សមតុល្យ :** ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំពុងមាននៅរតនាគារ។

**ចំណាំ** : គណនីនេះឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនី មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (លេខ ៤៤១១) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការដ្ឋ។

**៤១-គណនី បេឡាសាច់ប្រាក់ " លេខ ១៣០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ពីបេឡា ជាប្រចាំថ្ងៃ។

**ការកត់ត្រា៖**

ឥណពន្ធ : កត់ត្រាចំនួនសាច់ប្រាក់ដែលបានបង់ចូលបេឡា

ឥណទាន : កត់ត្រាចំនួនសាច់ប្រាក់ដែលបានចំណាយពីបេឡា

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនសាច់ប្រាក់ ដែលកំពុងមាននៅក្នុងបេឡា។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី បេឡាសាច់ប្រាក់នៅរតនាគារកណ្តាល (លេខ ១៣០១១), នៅរតនាគាររាជធានី ខេត្ត (លេខ ១៣០១២), នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (លេខ ១៣០១៣), នៅអគ្គនាយកដ្ឋានពន្ធដារ (លេខ ១៣០១៤), នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល (លេខ ១៣០១៥) និងនៅអង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ (លេខ ១៣០១៦)។

**៤២-គណនី រដ្ឋទេយ្យករបុរេប្រទាន ថវិកាមិនមែនកម្មវិធី " លេខ ១៤០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរដ្ឋទេយ្យបុរេប្រទាន សម្រាប់ថវិកាមិនមែនកម្មវិធី ដែលបានទទួលពីរតនាគារ ឬពីធនាគារ តាមរយៈរដ្ឋទេយ្យករបុរេប្រទាន។

**ការកត់ត្រា៖**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនរដ្ឋទេយ្យករបុរេប្រទានជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានទូទាត់ តាមរយៈអាណត្តិបើកប្រាក់

- កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានបង់ជាសាច់ប្រាក់ចូលរតនាគារ ឬធនាគារ ដើម្បីជម្រះរដ្ឋទេយ្យបុរេប្រទាន

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយរតនាគារ ឬ អង្គភាពសាមី។

**ចំណាំ** : - ការគណនា ការបង្កើន ឬការបន្ថយកំរិតកំណត់រដ្ឋទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី គឺធ្វើនៅក្រៅកិច្ចបញ្ជិកាគណនេយ្យ។

- គណនីនេះ ត្រូវមានតំរូវហត្ថលេខារបស់រដ្ឋទេយ្យករបុរេប្រទាន និងត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

- អគ្គនាយកដ្ឋានរតនាគារជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ អង្គភាពប្រហាក់ប្រហែល អាចបង្កើតបន្ថែមអនុគណនីនៃគណនី លេខ ១៤០១ សម្រាប់តាមដានជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ទៅតាមតម្រូវការចាំបាច់។

**៤៣-គណនី រដ្ឋទេយ្យករបុរេប្រទាន ថវិកាកម្មវិធី " លេខ ១៤០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាតាមកម្មវិធី ដែលបានទទួលពីរតនាគារ ឬ ពីធនាគារ តាមរយៈរដ្ឋទេយ្យករបុរេប្រទាន។

**ការកត់ត្រា៖**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនរដ្ឋទេយ្យករបុរេប្រទានជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានទូទាត់ តាមរយៈអាណត្តិបើកប្រាក់

- កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានបង់ជាសាច់ប្រាក់ចូលរតនាគារ ឬធនាគារ ដើម្បីជម្រះរដ្ឋទេយ្យបុរេប្រទាន

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយរតនាគារ ឬ អង្គភាពសាមី។

**ចំណាំ** : - ការគណនា ការបង្កើន ឬ ការបន្ថយកំរិតកំណត់រដ្ឋទេយ្យបុរេប្រទាន ថវិកាកម្មវិធី គឺធ្វើនៅក្រៅកិច្ចបញ្ជិកាគណនេយ្យ។

- គណនីនេះ ត្រូវមានតំរូវហត្ថលេខារបស់រដ្ឋទេយ្យករបុរេប្រទាន និងត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

- អគ្គនាយកដ្ឋានរតនាគារជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ អង្គភាពប្រហាក់ប្រហែល អាចបង្កើតបន្ថែមអនុគណនីនៃគណនី លេខ ១៤០២ សម្រាប់តាមដានជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ទៅតាមតម្រូវការចាំបាច់។

**៤៤-គណនី អ្នកជាប់ពន្ធ " លេខ ១៥០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បំណុលសារពើពន្ធដែលត្រូវប្រមូលពីសហគ្រាស ក្រុមហ៊ុន ឬរូបវន្តបុគ្គល។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រាទៅក្នុងគណនីនេះ គឺយោងតាមរបាយការណ៍ ឬ សលាកបត្របង់ចំណូលថវិការបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ និងសាខា។

**ការកត់ត្រា៖**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធគយនិងពន្ធដារដែលត្រូវប្រមូល (ខាងឥណពន្ធនៃគណនីនេះបដិភាគនឹងខាងឥណទាននៃគណនី ចំណូលសារពើពន្ធត្រូវប្រមូលបានកត់ត្រាទុកមុន លេខ ៤៨០១)

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធគយនិងពន្ធដារដែលសហគ្រាស ក្រុមហ៊ុន ឬរូបវន្តបុគ្គលបានសង និងទឹកប្រាក់បំណុលដែលបានបន្ថយ ឬ ជម្រះ (ខាងឥណទាននៃគណនីនេះបដិភាគនឹងខាងឥណពន្ធនៃគណនី ចំណូលសារពើពន្ធត្រូវប្រមូលបានកត់ត្រាទុកមុន លេខ ៤៨០១)

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បំណុលពន្ធគយនិងពន្ធដារ ដែលត្រូវប្រមូល។

**ចំណាំ** :- ការកត់ត្រាខាងឥណទាននៃគណនីនេះ គឺទន្ទឹមនឹងលេខនាចំណូលពន្ធ ដែលបានកត់ត្រាខាងឥណពន្ធ គណនី ហិរញ្ញវត្ថុ និងខាងឥណទាន គណនី ចំណូលថវិកា។

- រាល់លើកនៃការបង់ប្រាក់ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ត្រូវធ្វើការវិភាគ និង ផ្តល់ព័ត៌មានដល់រតនាគារដើម្បីកត់ត្រាជាចំណូលពន្ធក្នុងឆ្នាំ និងជាចំណូលពីបំណុលពន្ធឆ្នាំមុន។
- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គភាពទទួលបន្ទុកប្រមូលចំណូលសារពើពន្ធ។

**៤៥-គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ) "លេខ ១៥០២" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលត្រូវប្រមូលពីសហគ្រាស ក្រុមហ៊ុន ឬ រូបវន្តបុគ្គល។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រា គឺយោងតាមរបាយការណ៍ ឬសលាកបត្របង់ចំណូលថវិការបស់អង្គភាពដែលមានការពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលនេះ។

**ការកត់ត្រា:**

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលត្រូវប្រមូល

- កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលត្រូវប្រមូល (ខាងឥណពន្ធនៃគណនីនេះ បដិភាគនឹងខាងឥណទាននៃគណនី ចំណូលមិនមែនសារពើពន្ធត្រូវប្រមូលបានកត់ត្រាទុកមុន លេខ ៤៨០២)

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធ ដែលប្រមូលបាន

- កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលសហគ្រាស ក្រុមហ៊ុន ឬរូបវន្តបុគ្គលបានបង់ និងទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលបានបន្ថយ ឬ ជម្រះ (ខាងឥណទាននៃគណនីនេះ បដិភាគនឹងខាងឥណពន្ធនៃគណនី ចំណូលមិនមែនសារពើពន្ធត្រូវប្រមូលបានកត់ត្រាទុកមុន លេខ ៤៨០២)

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធ ដែលត្រូវប្រមូល។

**ចំណាំ** :- ការកត់ត្រាខាងឥណទាននៃគណនីនេះ គឺទន្ទឹមនឹងលេខនាចំណូលមិនមែនសារពើពន្ធ ដែលបានកត់ត្រាខាង ឥណពន្ធ គណនី ហិរញ្ញវត្ថុ និងខាងឥណទាន គណនី ចំណូលថវិកា។

- រាល់លើកនៃការបង់ប្រាក់ អង្គភាពគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការវិភាគនិងផ្តល់ព័ត៌មានដល់រតនាគារដើម្បីកត់ត្រាជាចំណូលមិនមែនសារពើពន្ធក្នុងឆ្នាំ និងជាចំណូលពីបំណុលមិនមែនសារពើពន្ធឆ្នាំមុន។
- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គភាពគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

**៤៦-គណនី ឧបត្ថម្ភធន និងចំណូលថវិកាដែលត្រូវទទួល "លេខ ១៥០៣" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភធននិងចំណូលថវិកាដែលត្រូវទទួលនិងបានទទួលពីក្រសួង ស្ថាប័ន និងអតិថិជន។

**ការកត់ត្រា:**

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភធនដែលត្រូវទទួល

- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលត្រូវទទួល

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភធនដែលបានទទួល

- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានទទួល

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ឧបត្ថម្ភធននិងចំណូលថវិកា ដែលត្រូវទទួលជាបន្ត។

**ចំណាំ** :- ការកត់ត្រាខាងឥណពន្ធនៃគណនីនេះ យោងតាមប្រកាសនៃការបែងចែកឥណទានថវិកា (ឧបត្ថម្ភធន) និងយោងតាម

វិក្កយបត្រ ឬកិច្ចសន្យា (ចំណូលថវិកា)។

- គណនីនេះត្រូវចែកជា អនុគណនី ឧបត្ថម្ភធនដែលត្រូវទទួល (លេខ ១៥០៣១) និងចំណូលថវិកាដែលត្រូវទទួល (លេខ ១៥០៣២)។

**៤៧-អនុគណនី ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់ដំណើរការ " លេខ ១៥០៥១ " :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយជាបណ្តោះអាសន្នលើការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយចរន្ត ដោយយោងតាមលិខិតសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអគ្គនាយកដ្ឋានរតនាគារជាតិ ឬ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬប្រធានអង្គភាពប្រហាក់ប្រហែល ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានបើកផ្តល់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ ដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទូទាត់ដោយអាណត្តិបើកប្រាក់ ឬដោយបង់ជាសាច់ប្រាក់ ឬបង់ចូលគណនីចរន្តនៅធនាគារ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលបានបើកផ្តល់ ហើយពុំទាន់បានទូទាត់។

**ចំណាំ** :- អនុគណនីនេះ ត្រូវតាមដានលម្អិតទៅតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ដែលបានទទួលប្រាក់បុរេប្រទាន និងតាមដានទៅតាមរូបិយប័ណ្ណនីមួយៗ។

- អនុគណនីនេះ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**៤៨-អនុគណនី ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ " លេខ ១៥០៥២ " :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានចំណាយជាបណ្តោះអាសន្នលើការផ្តល់បុរេប្រទានសាច់ប្រាក់សម្រាប់ចំណាយវិនិយោគ ដោយយោងតាមលិខិតសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអគ្គនាយកដ្ឋានរតនាគារជាតិ ឬនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬប្រធានអង្គភាពប្រហាក់ប្រហែល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានបើកផ្តល់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ ដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បុរេប្រទាន ដែលបានទូទាត់ដោយអាណត្តិបើកប្រាក់ ឬ ដោយបង់ជាសាច់ប្រាក់ ឬបង់ចូលគណនីចរន្តនៅធនាគារ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលបានបើកផ្តល់ ហើយពុំទាន់បានទូទាត់។

**ចំណាំ** :- អនុគណនីនេះ ត្រូវតាមដានលម្អិតទៅតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ដែលបានទទួលប្រាក់បុរេប្រទាន និងតាមដានទៅតាមរូបិយប័ណ្ណនីមួយៗ។

- អនុគណនីនេះ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**៤៩-អនុគណនី សាច់ប្រាក់បានផ្ទេរទៅរតនាគាររាជធានី ខេត្ត រង់ចាំធ្វើនិយ័តកម្ម " លេខ ១៥០៥៣ " :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនសាច់ប្រាក់ដែលរតនាគារថ្នាក់កណ្តាលបានផ្ទេរទៅរតនាគាររាជធានី ខេត្ត តាមរយៈធនាគារជាតិនៃកម្ពុជា ឬធនាគារពាណិជ្ជដៃគូ ហើយរង់ចាំការទូទាត់ជាមួយប្រកាសឥណទាន ដែលរតនាគាររាជធានី ខេត្ត ត្រូវប្រគល់មកវិញ នៅពេលក្រោយ។ អនុគណនីលេខ ១៥០៥៣ ជាប្រភេទគណនីរង់ចាំ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរទៅរតនាគាររាជធានី ខេត្ត ហើយពុំទាន់បានទទួលប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះជាមួយប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានផ្ទេរទៅរតនាគាររាជធានី ខេត្ត ហើយរង់ចាំការជម្រះជាមួយប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត។

**ចំណាំ** :- អនុគណនីនេះ ត្រូវតាមដានលម្អិតទៅតាមរតនាគាររាជធានី ខេត្ត ដែលត្រូវទទួលសាច់ប្រាក់។

- អនុគណនីនេះ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**៥០-អនុគណនី ចំណាយមុនការធ្វើអាណត្តិកិច្ច “ លេខ ១៥០៥៤ ” :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយ (ប្រតិបត្តិការគនៈវត្ថុ) លើការទូទាត់ប្រាក់ដើម ការប្រាក់សេវាធនាគារ សេវាគេឡិច និងចំណាយផ្សេងៗទៀតដែលបានកាត់ទុកមុន ដោយពុំទាន់បានកត់ត្រាជាចំណាយថវិកាជាស្ថាពរ ហើយរង់ចាំអាណត្តិបើកប្រាក់ដើម្បីធ្វើនិយ័តកម្ម។ អនុគណនីលេខ ១៥០៥៤ ជាប្រភេទគណនីរង់ចាំ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនប្រាក់ដើម ការប្រាក់ សេវាធនាគារ សេវាគេឡិច និងចំណាយផ្សេងៗទៀត ដែលបានកាត់ទុកមុន

ឥណទាន : កត់ត្រាចំនួនប្រាក់ដើម ការប្រាក់ សេវាធនាគារ សេវាគេឡិច និងចំណាយផ្សេងៗទៀត ដែលបានទូទាត់ជាមួយអាណត្តិបើកប្រាក់ ឬ បង្វែរសងវិញជាសាច់ប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនប្រាក់ដើម ការប្រាក់ សេវាធនាគារ សេវាគេឡិច និងចំណាយផ្សេងៗទៀត ដែលបានកាត់ទុកមុន តែពុំទាន់បានទូទាត់។

**៥១-អនុគណនី អ្នកផ្គត់ផ្គង់ ឥណាយិក “ លេខ ១៥០៥៥ ” :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់មុនជូនអ្នកផ្គត់ផ្គង់ សម្ភារៈ សេវា និងទំនិញ។ អនុគណនីនេះត្រូវទូទាត់កាត់កងជាមួយនឹងគណនីអ្នកផ្គត់ផ្គង់ នៅពេលមានអាណត្តិបើកប្រាក់ត្រូវទូទាត់ទៅអ្នកទាំងនោះ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់មុនជូនទៅអ្នកផ្គត់ផ្គង់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ ដោយបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់កងជាមួយនឹងចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់

- កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់បានបង្វិលសងមកវិញ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ត្រូវទារពីអ្នកផ្គត់ផ្គង់។

<u>**ចំណាំ**</u> : - អនុគណនីនេះ ពុំមានគិរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ។

- អនុគណនីនេះ ត្រូវតាមដានលម្អិតទៅតាមអ្នកផ្គត់ផ្គង់។

**៥២-អនុគណនី បុរេប្រទានបៀវត្ស លាភការ និងប្រាក់កម្រៃ “ លេខ ១៥០៥៦ ” :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានផ្តល់បុរេប្រទានសម្រាប់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភ ដែលមានលក្ខណៈប្រហាក់ប្រហែលបៀវត្ស ជូនមន្ត្រីរាជការ បុគ្គលិក និងក្រុមប្រឹក្សា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានផ្តល់បុរេប្រទាន

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទូទាត់ ដោយអាណត្តិបើកប្រាក់ ឬជាសាច់ប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលបានផ្តល់ ហើយពុំទាន់បានទូទាត់ជម្រះ។

<u>**ចំណាំ**</u> : - អនុគណនីនេះ ត្រូវតាមដានលម្អិតទៅតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ដែលបានទទួលប្រាក់បុរេប្រទាន។

- អនុគណនីនេះ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**៥៣-អនុគណនី ចំណាយផ្សេងៗរង់ចាំការដោះស្រាយ “ លេខ ១៥០៥៨ ” :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយ ឬមានលក្ខណៈប្រហាក់ប្រហែលចំណាយ ដែលរង់ចាំការដោះស្រាយ ឬផ្ទេរទៅគណនីសកម្មផ្សេងទៀត។ គណនីលេខ ១៥០៥៨ ជាប្រភេទគណនីរង់ចាំ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយបានដោះស្រាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ។

<u>**ចំណាំ**</u> : អនុគណនីនេះត្រូវតាមដានទៅតាមមុខសញ្ញានីមួយៗ និងតាមរូបិយប័ណ្ណនីមួយៗ។

**៥៤-អនុគណនី ទីសមតាពបេឡា ឥណាយិក " លេខ ១៥០៦១ " :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់លំអៀងខ្វះក្នុងបេឡារវាងបញ្ជីបេឡា និងសាច់ប្រាក់ជាក់ស្តែង ដោយយោងតាមបញ្ជីសារពើភ័ណ្ឌ និងប័ណ្ណចំណាយបេឡា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់លំអៀងខ្វះក្នុងបេឡាត្រូវដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់លំអៀងខ្វះក្នុងបេឡាបានដោះស្រាយជាចំណាយថវិកា ឬបានសងជាសាច់ប្រាក់

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់លំអៀងខ្វះក្នុងបេឡា ដែលពុំទាន់បានដោះស្រាយ។

**៥៥-អនុគណនី ឱនភាពគណនេយ្យត្រូវដោះស្រាយ " លេខ ១៥០៦២ " :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ឱនភាពរបស់គណនេយ្យករ ដែលបណ្តាលមកពីការផ្ទេរប្រាក់លើសពីសមតុល្យឥណទាយី ឬ ការគណនាបញ្ជីខុស។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលខ្វះ ឬបាត់ក្នុងបញ្ជីគណនេយ្យហើយរង់ចាំការដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលខ្វះ ឬបាត់លើបញ្ជីគណនេយ្យដែលបានដោះស្រាយជាចំណាយថវិកា ឬបានសងប្រាក់វិញ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ឱនភាពគណនេយ្យ ដែលពុំទាន់បានដោះស្រាយ។

**<u>ចំណាំ</u>** : អនុគណនីនេះត្រូវតាមដានទៅតាមអ្នកទទួលខុសត្រូវទៅលើឱនភាពនីមួយៗ។

**៥៦-អនុគណនី ឥណាយិកផ្សេងៗ " លេខ ១៥០៦៨ " :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវទារ ឬ ត្រូវដោះស្រាយផ្សេងៗ ក្រៅពីប្រាក់ពន្ធ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗត្រូវទារ ឬ ត្រូវដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗដែលបានដោះស្រាយ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ផ្សេងៗត្រូវទារ ឬ ត្រូវដោះស្រាយ។

**<u>ចំណាំ</u>** :
- អនុគណនីនេះ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំនីមួយៗ។
- អនុគណនីនេះ ជាប្រភេទអនុគណនីរង់ចាំ។

**៥៧-គណនី ការឱ្យខ្ចីរយៈពេលខ្លី " លេខ ១៦០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដើមនៃការឱ្យខ្ចីរយៈពេលខ្លី (តិចជាងមួយឆ្នាំ) ដែលរាជរដ្ឋាភិបាលបានផ្តល់ជូនគ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ សមូហភាពមូលដ្ឋាន ក្រុមហ៊ុន អង្គការ ដើម្បីបម្រើឱ្យទិសដៅវិនិយោគរយៈពេលខ្លី។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដើមឱ្យខ្ចី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមឱ្យខ្ចី ដែលបានសងវិញ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដើមឱ្យខ្ចី ដែលពុំទាន់បានសងមកវិញ។

**<u>ចំណាំ</u>** :
- គណនីនេះត្រូវតាមដានទៅតាមមុខសញ្ញាដែលបានឱ្យប្រាក់ខ្ចី។
- ការកត់ត្រានៅក្នុងគណនីលេខ ១៦០១ គឺកត់ត្រាតែចំនួនប្រាក់ដើមឱ្យខ្ចី និងបានសងមកវិញ រីឯកម្រៃការប្រាក់ ដែលបានទទួល គឺត្រូវកត់ត្រានៅក្នុងគណនីចំណូលថវិកាពីការប្រាក់។

**៥៨-គណនី ចំណែកនៃប្រាក់ឱ្យខ្ចី " លេខ ១៦០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណែកនៃប្រាក់ឱ្យខ្ចីដែលបានផ្ទេរចេញពីគណនីការឱ្យខ្ចីរយៈពេលវែង ដោយយោងតាមតារាងកាលកំណត់ត្រូវសង ឬ កិច្ចសន្យារវាងរាជរដ្ឋាភិបាល និងគ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ សមូហភាពមូលដ្ឋាន ក្រុមហ៊ុន អង្គភាព ឬ អង្គការ...។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណែកនៃប្រាក់ឱ្យខ្ចីដែលត្រូវទារ

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណែកនៃប្រាក់ឱ្យខ្ចីដែលបានសងមកវិញ

- កត់ត្រាចំនួនទឹកប្រាក់ចំណែកនៃប្រាក់ឱ្យខ្ចីដែលទារមិនបាន ហើយត្រូវជម្រះជាមួយគណនីចំណាយថវិកា

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណែកនៃប្រាក់ឱ្យខ្ចីដែលពុំទាន់បានទូទាត់វិញ។

<u>ចំណាំ</u> :- គណនីនេះត្រូវតាមដានលម្អិតទៅតាមមុខសញ្ញាដែលបានឱ្យប្រាក់ខ្ចី។

- ការកត់ត្រានៅក្នុងគណនីលេខ ១៦០២ គឺកត់ត្រាតែចំនួនប្រាក់ដើមឱ្យខ្ចី និងបានសងមកវិញ រីឯកម្រៃការប្រាក់ ដែលបានទទួល គឺត្រូវកត់ត្រាទៅក្នុងគណនីចំណូលថវិកាពីការប្រាក់។

- ខាងឥណពន្ធនៃគណនីនេះ មានការពាក់ព័ន្ធនឹងគណនីការឱ្យខ្ចីរយៈពេលវែង។

**៥៩-គណនី សន្និធិសម្ភារៈផ្គត់ផ្គង់ថែទាំ " លេខ ១៧០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ចូល បញ្ចេញ និងសន្និធិនៅសល់នៃសម្ភារៈផ្គត់ផ្គង់ថែទាំ។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រានៅក្នុងគណនីសន្និធិជាបរិយាទានលទ្ធកម្ម ឬ បរិយាទានផលិតកម្ម និងត្រូវកំណត់ដោយវិធីសាស្ត្រវាយតម្លៃតាមមធ្យមភាគ ឬវិធីសាស្ត្រចូលមុនចេញមុន ឬវិធីសាស្ត្រផ្សេងទៀត ដែលក្រសួង ស្ថាប័ន អង្គភាព សម្រេចយកមកអនុវត្ត។

**ការកត់ត្រា:**

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចូលជាប្រចាំ

- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចេញ

- កត់ត្រាចំនួនទឹកប្រាក់ដើមគ្រាដែលបានធ្វើមោឃកម្ម

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា។

<u>ចំណាំ</u> :- គណនីនេះកត់ត្រាបដិភាគនឹងគណនីបម្រែបម្រួលសន្និធិដែលពាក់ព័ន្ធ។

- គណនីនេះត្រូវចែកចេញជា អនុគណនី សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ (លេខ ១៧០១១), សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ, ប្រាសាទ និងសំណង់ផ្សេងៗ (លេខ ១៧០១២), សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ (១៧០១៣), សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ (លេខ ១៧០១៤), ប្រេងឥន្ធនៈនិងប្រេងរំអិល (លេខ ១៧០១៥) និងសម្ភារៈផ្គត់ផ្គង់ថែទាំផ្សេងៗ (លេខ ១៧០១៨)។

**៦០-គណនី សន្និធិសម្ភារៈផ្គត់ផ្គង់រដ្ឋបាល " លេខ ១៧០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ចូល បញ្ចេញ និងសន្និធិនៅសល់នៃសម្ភារៈផ្គត់ផ្គង់រដ្ឋបាល។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រា នៅក្នុងគណនីសន្និធិជាបរិយាទានលទ្ធកម្ម ឬបរិយាទានផលិតកម្ម និងត្រូវកំណត់ដោយវិធីសាស្ត្រវាយតម្លៃតាមមធ្យមភាគ ឬវិធីសាស្ត្រចូលមុន ចេញមុន ឬវិធីសាស្ត្រផ្សេងទៀត ដែលក្រសួង ស្ថាប័ន អង្គភាព សម្រេចយកមកអនុវត្ត។

**ការកត់ត្រា:**

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចូលជាប្រចាំ

- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចេញ

- កត់ត្រាចំនួនទឹកប្រាក់ដើមគ្រាដែលបានធ្វើមោឃកម្ម

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា។

<u>ចំណាំ</u> :- គណនីនេះ កត់ត្រាបដិភាគនឹងគណនីបម្រែបម្រួលសន្និធិដែលពាក់ព័ន្ធ។

- គណនីនេះត្រូវចែកចេញជា អនុគណនី សម្ភារៈការិយាល័យនិងការបោះពុម្ព (លេខ ១៧០២១), សៀវភៅមើលនិងឯកសារ (លេខ ១៧០២២) និង សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ (១៧០២៨)។

**៦១-គណនី សន្និធិស្បៀងអាហារ និងផលិតផលកសិកម្ម " លេខ ១៧០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ចូល បញ្ចេញ និងសន្និធិនៅសល់នៃស្បៀងអាហារ និងផលិតផលកសិកម្ម។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រានៅក្នុងគណនីសន្និធិជា បរិយាទានលទ្ធកម្ម ឬបរិយាទានផលិតកម្ម និងត្រូវកំណត់ដោយវិធីសាស្ត្រវាយតម្លៃតាមមធ្យមភាគ ឬវិធីសាស្ត្រចូលមុន ចេញមុន ឬវិធីសាស្ត្រផ្សេងទៀត ដែលក្រសួង ស្ថាប័ន អង្គភាព សម្រេចយកមកអនុវត្ត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចូលជាប្រចាំ

- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចេញ

- កត់ត្រាចំនួនទឹកប្រាក់ដើមគ្រាដែលបានធ្វើមោឃកម្ម

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា។

**<u>ចំណាំ</u>** : - គណនីនេះ កត់ត្រាបដិភាគនឹងគណនីបម្រែបម្រួលសន្និធិដែលពាក់ព័ន្ធ។

- គណនីនេះត្រូវចែកចេញជា អនុគណនី ស្បៀង (លេខ ១៧០៣១), ចំណីសត្វ (លេខ ១៧០៣២), ពូជនិងកូនរុក្ខជាតិ (លេខ ១៧០៣៣), ផលិតផលការពារសុខុមាលភាពរុក្ខជាតិនិងដី (លេខ ១៧០៣៤), ពូជសត្វ និសថ និងវត្ថុធាតុសម្រាប់បសុពេទ្យ (១៧០៣៥) និង ស្បៀងអាហារ និងផលិតផលកសិកម្មផ្សេងៗ (១៧០៣៨)។

**៦២-គណនី សន្និធិសំលៀកបំពាក់ និងការតុបតែង " លេខ ១៧០៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ចូល បញ្ចេញ និងសន្និធិនៅសល់នៃសំលៀកបំពាក់ និងការតុបតែង។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រា នៅក្នុងគណនីសន្និធិជាបរិយាទានលទ្ធកម្ម ឬបរិយាទានផលិតកម្ម និងត្រូវកំណត់ដោយវិធីសាស្ត្រវាយតម្លៃ តាមមធ្យមភាគ ឬវិធីសាស្ត្រចូលមុន ចេញមុន ឬវិធីសាស្ត្រផ្សេងទៀត ដែលក្រសួង ស្ថាប័ន អង្គភាព សម្រេចយកមកអនុវត្ត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចូលជាប្រចាំ

- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចេញ

- កត់ត្រាចំនួនទឹកប្រាក់ដើមគ្រាដែលបានធ្វើមោឃកម្ម

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា។

**<u>ចំណាំ</u>** : - គណនីនេះកត់ត្រាបដិភាគនឹងគណនីបម្រែបម្រួលសន្និធិដែលពាក់ព័ន្ធ។

- គណនីនេះត្រូវចែកជា អនុគណនី ឯកសណ្ឋាន (លេខ ១៧០៤១), សំលៀកបំពាក់ការពារសុវត្ថិភាព (លេខ ១៧០៤២), មេដាយ (គ្រឿងឥស្សរិយយស) (លេខ ១៧០៤៣) និង សំលៀកបំពាក់និងការតុបតែងផ្សេងៗ (លេខ ១៧០៤៨)។

**៦៣-គណនី សន្និធិសម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ " លេខ ១៧០៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ចូល បញ្ចេញ និងសន្និធិនៅសល់នៃសម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រានៅក្នុងគណនីសន្និធិជាបរិយាទានលទ្ធកម្ម ឬបរិយាទានផលិតកម្ម និងត្រូវកំណត់ដោយវិធីសាស្ត្រវាយតម្លៃតាមមធ្យមភាគ ឬវិធីសាស្ត្រចូលមុន ចេញមុន ឬវិធីសាស្ត្រផ្សេងទៀត ដែលក្រសួង ស្ថាប័ន អង្គភាព សម្រេចយកមកអនុវត្ត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចូលជាប្រចាំ

- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចេញ

- កត់ត្រាចំនួនទឹកប្រាក់ដើមគ្រាដែលបានធ្វើមោឃកម្ម

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា។

**<u>ចំណាំ</u>** : - គណនីនេះ កត់ត្រាបដិភាគនឹងគណនីបម្រែបម្រួលសន្និធិដែលពាក់ព័ន្ធ។

- គណនីនេះត្រូវចែកជា អនុគណនី សម្ភារៈនិងបរិក្ខារបច្ចេកទេស (លេខ ១៧០៥១), សង្ហារឹម (លេខ ១៧០៥២), សម្ភារៈប្រើប្រាស់ (១៧០៥៣), សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន (១៧០៥៤) និងសម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ (១៧០៥៨)។

**៦៤-គណនី សន្និធិសម្ភារៈបរិក្ខារថែទាំសុខភាព "លេខ ១៧០៧":**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ចូល បញ្ចេញ និងសន្និធិនៅសល់នៃសម្ភារៈបរិក្ខារថែទាំសុខភាព។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រា នៅក្នុងគណនីសន្និធិជាបរិយាទានលទ្ធកម្ម ឬបរិយាទានផលិតកម្ម និងត្រូវកំណត់ដោយវិធីសាស្ត្រវាយតម្លៃតាមមធ្យមភាគ ឬវិធីសាស្ត្រចូលមុន ចេញមុន ឬវិធីសាស្ត្រផ្សេងទៀត ដែលក្រសួង ស្ថាប័ន អង្គភាព សម្រេចយកមកអនុវត្ត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចូលជាប្រចាំ

- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចេញ

- កត់ត្រាចំនួនទឹកប្រាក់ដើមគ្រាដែលបានធ្វើមោឃកម្ម

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា។

**<u>ចំណាំ</u>** : - គណនីនេះ កត់ត្រាបដិភាគនឹងគណនីបម្រែបម្រួលសន្និធិដែលពាក់ព័ន្ធ។

- គណនីនេះត្រូវចែកជា អនុគណនី បំពង់ហ្គាសនិងអុកស៊ីសែន (លេខ ១៧០៧១), សម្ភារៈបរិក្ខារពេទ្យ (១៧០៧២) និងសម្ភារៈបរិក្ខារថែទាំសុខភាពផ្សេងៗ (លេខ ១៧០៧៨)។

**៦៥-គណនី សន្និធិសម្ភារៈផ្គត់ផ្គង់ផ្សេងៗ "លេខ ១៧០៨":**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ចូល បញ្ចេញ និងសន្និធិនៅសល់នៃសម្ភារៈផ្គត់ផ្គង់ផ្សេងៗ ដែលពុំមានរៀបរាប់នៅក្នុងគណនីខាងលើ។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រា នៅក្នុងគណនីសន្និធិជាបរិយាទានលទ្ធកម្ម ឬបរិយាទានផលិតកម្ម និងត្រូវកំណត់ដោយវិធីសាស្ត្រវាយតម្លៃតាមមធ្យមភាគ ឬវិធីសាស្ត្រចូលមុន ចេញមុន ឬវិធីសាស្ត្រផ្សេងទៀត ដែលក្រសួង ស្ថាប័ន អង្គភាព សម្រេចយកមកអនុវត្ត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចូលជាប្រចាំ

- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដែលបានបញ្ចេញ

- កត់ត្រាចំនួនទឹកប្រាក់ដើមគ្រាដែលបានធ្វើមោឃកម្ម

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃសន្និធិនៅចុងគ្រា។

**<u>ចំណាំ</u>** : គណនីនេះ កត់ត្រាបដិភាគនឹងគណនីបម្រែបម្រួលសន្និធិសម្ភារៈផ្គត់ផ្គង់ផ្សេងៗ។

**៦៦-គណនី សោហ៊ុយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ "លេខ ២០០៣":**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលចាត់ជាចំណាយវិនិយោគ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលបានជម្រះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត និងតម្លៃនៅសល់

**សមតុល្យ :** ឥណាយិក បង្ហាញតម្លៃនៃការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលបានចំណាយ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ (លេខ ២០០៣១) និងផ្សេងៗ (លេខ ២០០៣៨)។

**៦៧-គណនី ប្រកាសនីយបត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល " លេខ ២០០៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយដើម្បីបង្កើត ឬ ទិញប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានទិញ ឬ បង្កើតប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ផ្ទេរ ឬ ជម្រុះ

**សមតុល្យ** : ឥណាយិក បង្ហាញតម្លៃប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែលនិងកម្មវិធីកុំព្យូទ័រ ដែល កំពុងមាន។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ប្រកាសនីយបត្រ (លេខ ២០០៥១), អាជ្ញាប័ណ្ណ (លេខ ២០០៥២), សិទ្ធិប្រហាក់ប្រហែល (លេខ ២០០៥៣), កម្មវិធីកុំព្យូទ័រ (លេខ ២០០៥៤) និងផ្សេងៗ (លេខ ២០០៥៨)។

**៦៨-គណនី ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ " លេខ ២១០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាន្ធូវតម្លៃដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ ដែលបានទិញ បានពីអំណោយ និងបានពីរូបភាពផ្សេងទៀតហើយបានបញ្ចូលជាទ្រព្យសម្បត្តិ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតម្លៃដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិដែលបានបញ្ចូលជាទ្រព្យសម្បត្តិ

ឥណទាន : កត់ត្រាតម្លៃដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិដែលបានបន្ថយដោយលក់ អំណោយ ផ្ទេរ ឬ ជម្រុះ

**សមតុល្យ** : ឥណាយិក បង្ហាញតម្លៃដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិ ដែលកំពុងមាន។

**<u>ចំណាំ</u>** : - គណនីនេះត្រូវចែកជាអនុគណនី ដីធ្លី (លេខ ២១០១១), ដីរ៉ែ (លេខ ២១០១២) និងសម្បត្តិធម្មជាតិផ្សេងៗ (លេខ ២១០១៨)។

- គណនីដីធ្លីពុំមានការគិតរំលស់ឡើយ។

**៦៩-គណនី ការរៀបចំកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ " លេខ ២១០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការរៀបចំកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រុះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត និងគណនីតម្លៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ ឬ ជម្រុះ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗដែលពុំទាន់បានជម្រុះ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ការរៀបចំកែលម្អដីធ្លី (លេខ ២១០២១), ការរៀបចំកែលម្អដីរ៉ែ (លេខ ២១០២២) និងការរៀបចំកែលម្អសម្បត្តិធម្មជាតិផ្សេងៗ (លេខ ២១០២៨)។

**៧០-គណនី សំណង់អគារ និងការកែលម្អ " លេខ ២១០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការទិញ ការសាងសង់ និងការកែលម្អអគារ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការទិញ ការសាងសង់ និងការកែលម្អអគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រុះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត និងគណនីតម្លៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ ឬ ជម្រុះ ឬ ផ្ទេរ

**សមតុល្យ** : ឥណពិន្ទុ បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើការទិញ ការសាងសង់ និងការកែលម្អអគារ ដែលពុំទាន់បានជម្រះ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សំណង់អគារ (លេខ ២១០៣១), ការកែលម្អអគារ (លេខ ២១០៣២) និងសំណង់ផ្សេង (លេខ ២១០៣៨)។

**៧១-គណនី ហេដ្ឋារចនាសម្ព័ន្ធ "លេខ ២១០៤" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាតម្លៃនៃហេដ្ឋារចនាសម្ព័ន្ធដែលបានទិញ សាងសង់ ឬបានពីអំណោយ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតម្លៃហេដ្ឋារចនាសម្ព័ន្ធដែលបានបញ្ចូលជាទ្រព្យសម្បត្តិ

ឥណទាន : កត់ត្រាតម្លៃហេដ្ឋារចនាសម្ព័ន្ធដែលបានបន្ថយដោយលក់ អំណោយ ផ្ទេរ ឬ ជម្រះ

**សមតុល្យ** : ឥណពិន្ទុ បង្ហាញតម្លៃហេដ្ឋារចនាសម្ព័ន្ធ ដែលកំពុងមាន។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ផ្លូវថ្នល់ ផ្លូវទឹក (លេខ ២១០៤១), ធារាសាស្ត្រ (លេខ ២១០៤២), អាយស្ម័យយាន (លេខ ២១០៤៣), អាកាសយានដ្ឋាន (លេខ ២១០៤៤), ទូរគមនាគមន៍ (លេខ ២១០៤៥), អគ្គិសនី (លេខ ២១០៤៦), បណ្តាញបង្ហូរទឹក និងអនាម័យ (លេខ ២១០៤៧) និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (លេខ ២១០៤៨)។

**៧២-គណនី ផលិតកម្មបច្ចេកទេស សម្ភារ និងឧបករណ៍ "លេខ ២១០៥" :**

គណនីនេះ ប្រើសម្រាប់កត់ត្រានូវតម្លៃផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថឧបករណ៍ ដែលបានពីការទិញ ឬ បានពីអំណោយ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតម្លៃផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថឧបករណ៍ដែលបានបញ្ចូលជាទ្រព្យសម្បត្តិ

ឥណទាន : កត់ត្រាតម្លៃផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថឧបករណ៍ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ជម្រះ ឬ ផ្ទេរ

**សមតុល្យ** : ឥណពិន្ទុ បង្ហាញតម្លៃផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថឧបករណ៍ ដែលកំពុងមាន។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ផលិតកម្មបច្ចេកទេស (លេខ ២១០៥១), សម្ភារ (លេខ ២១០៥២), គ្រឿងឧបករណ៍ (ហត្ថឧបករណ៍) (លេខ ២១០៥៣) និងគ្រឿងសម្ភារផ្សេងៗ (លេខ ២១០៥៨)។

**៧៣-គណនី ស្នាដៃសិល្បៈ និងការប្រមូល (សន្សំ) "លេខ ២១០៦" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាតម្លៃនៃទ្រព្យសម្បត្តិ ដូចជា ស្នាដៃ ផ្ទាំងគំនូរ រូបបដិមាករ ចម្លាក់ វត្ថុបុរាណ សៀវភៅបុរាណ។ល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មជាស្នាដៃសិល្បៈនិងការប្រមូល (សន្សំ) ដែលបានបញ្ចូលជាទ្រព្យសម្បត្តិ

ឥណទាន : កត់ត្រាតម្លៃអចលកម្មជាស្នាដៃសិល្បៈនិងការប្រមូល (សន្សំ) ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ជម្រះ ឬ ផ្ទេរ

**សមតុល្យ** : ឥណពិន្ទុ បង្ហាញតម្លៃអចលកម្មជាស្នាដៃ ផ្ទាំងគំនូរ រូបបដិមាករ ចម្លាក់ វត្ថុបុរាណ សៀវភៅបុរាណ... ដែលកំពុងមាន។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ស្នាដៃសិល្បៈនិងការប្រមូល (សន្សំ) (លេខ ២១០៦១)។

**៧៤-គណនី អចលកម្មរូបីផ្សេងទៀត "លេខ ២១០៨" :**

គណនីនេះ ប្រើសម្រាប់កត់ត្រានូវតម្លៃអចលកម្មរូបីផ្សេងទៀត ដែលបានទិញ សាងសង់ និងបានពីអំណោយ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មរូបីដែលបានបញ្ចូលជាទ្រព្យសម្បត្តិ

ឥណទាន : កត់ត្រាតម្លៃអចលកម្មរូបីដែលបានបន្ថយដោយលក់ អំណោយ ផ្ទេរ ឬ ជម្រះ

**សមតុល្យ** : ឥណពិន្ទុ បង្ហាញតម្លៃអចលកម្មរូបីផ្សេងទៀត ដែលកំពុងមាន។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២១០៨១), សម្ភារ ឧបករណ៍ការិយាល័យ (លេខ ២១០៨២), សម្ភារ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ (លេខ ២១០៨៣), សត្វពាហនៈ (លេខ ២១០៨៤) និងអចលកម្មរូបីផ្សេងៗ (លេខ ២១០៨៨)។

**៧៥-គណនី សំណងកិច្ចសន្យាលើហេដ្ឋារចនាសម្ព័ន្ធ “ លេខ ២១០៩ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានចំណាយសងលើការរំលត់កិច្ចសន្យាជាមួយក្រុមហ៊ុន សហគ្រាស ដែលជាអ្នកសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ គណនីនេះ កត់ត្រាតម្លៃហេដ្ឋារចនាសម្ព័ន្ធដែលបានបញ្ចូលជាព្រទ្យសម្បត្តិ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយសងលើការរំលត់កិច្ចសន្យាសាងសង់ហេដ្ឋារចនាសម្ព័ន្ធ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះផ្ទេរតម្លៃហេដ្ឋារចនាសម្ព័ន្ធ ដែលបានពីការរំលត់កិច្ចសន្យា

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធ ដែលបានទទួលពីការរំលត់កិច្ចសន្យា។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ផ្លូវថ្នល់ ផ្លូវទឹក (លេខ ២១០៩១), ធារាសាស្ត្រ (លេខ ២១០៩២), អាយស្ម័យយាន (លេខ ២១០៩៣), អាកាសយានដ្ឋាន (លេខ ២១០៩៤), ទូរគមនាគមន៍ (លេខ ២១០៩៥), អគ្គិសនី (លេខ ២១០៩៦), បណ្តាញបង្ហូរទឹក និងអនាម័យ (លេខ ២១០៩៧) និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (លេខ ២១០៩៨)។

**៧៦-គណនី ទ្រព្យសម្បត្តិវិនិយោគរយៈពេលវែង “ លេខ ២២០១ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់តម្លៃទ្រព្យសម្បត្តិវិនិយោគមាន ដីធ្លី អគារ និងសំណង់ សម្រាប់ជួល ឬ លក់ ដើម្បីទទួលបានចំណូលពីទ្រព្យសម្បត្តិនេះ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់តម្លៃទ្រព្យសម្បត្តិវិនិយោគ ដីធ្លី អគារ និងសំណង់ ដែលបានបញ្ចូលជាទ្រព្យសម្បត្តិ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃទ្រព្យសម្បត្តិដែលបានបន្ថយដោយលក់ អំណោយ ផ្ទេរ ឬ ជម្រះ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃទ្រព្យសម្បត្តិវិនិយោគ ដីធ្លី អគារ និងសំណង់ ដែលកំពុងមាន។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ទ្រព្យសម្បត្តិវិនិយោគ ដីធ្លី (លេខ ២២០១១) និងទ្រព្យសម្បត្តិវិនិយោគ អគារ និងសំណង់ (លេខ ២២០១២)។

**៧៧-គណនី អចលកម្មអរូបី (កំពុងដំណើរការ) “ លេខ ២៣០០ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រានូវតម្លៃអចលកម្មអរូបី ដែលកំពុងដំណើរការសាងសង់ ឬផលិត។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មអរូបីដែលកំពុងដំណើរការសាងសង់ ផលិត

ឥណទាន : កត់ត្រាតម្លៃអចលកម្មអរូបីដែលបានផ្ទេរទៅគណនី អចលកម្មអរូបី ដែលពាក់ព័ន្ធ

**សមតុល្យ :** ឥណាយិក បង្ហាញតម្លៃអចលកម្មអរូបី ដែលកំពុងដំណើរការសាងសង់ ឬផលិត។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ (កំពុងដំណើរការ) (លេខ ២៣០០៣) និងប្រកាសនីយបត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល (កំពុងដំណើរការ) (លេខ ២៣០០៥)។

**៧៨-គណនី ការរៀបចំកែលម្អ ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ (កំពុងដំណើរការ) “ លេខ ២៣០២ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃការរៀបចំកែលម្អ ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ ដែលកំពុងដំណើរការ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការរៀបចំកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗដែលកំពុងដំណើរការ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរទៅគណនីការរៀបចំកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗដែលពាក់ព័ន្ធ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើការរៀបចំកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ ដែលកំពុងដំណើរការ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ការរៀបចំកែលម្អដីធ្លី (កំពុងដំណើរការ) (លេខ ២៣០២១), ការរៀបចំកែលម្អដីរ៉ែ (កំពុងដំណើរការ) (លេខ ២៣០២២) និងការរៀបចំកែលម្អសម្បត្តិធម្មជាតិផ្សេងៗ (កំពុងដំណើរការ) (លេខ ២៣០២៨)។

**៧៩-គណនី សំណង់អគារ និងការកែលម្អ (កំពុងដំណើរការ) " លេខ ២៣០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយលើសំណង់អគារ និងការកែលម្អ ដែលកំពុងដំណើរការសាងសង់និងកែលម្អ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយសាងសង់អគារ និងការកែលម្អដែលកំពុងដំណើរការ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរទៅគណនីសំណង់អគារ និងការកែលម្អ ដែលពាក់ព័ន្ធ

**សមតុល្យ :** ឥណពេិក បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើសំណង់អគារ និងការកែលម្អអគារ ដែលកំពុងដំណើរការ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សំណង់អគារ (កំពុងដំណើរការ) (លេខ ២៣០៣១), ការកែលម្អអគារ (កំពុងដំណើរការ) (លេខ ២៣០៣២) និងសំណង់ផ្សេងៗ (កំពុងដំណើរការ) (លេខ ២៣០៣៨)។

**៨០-គណនី ហេដ្ឋារចនាសម្ព័ន្ធ (កំពុងដំណើរការ) " លេខ ២៣០៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលកំពុងដំណើរការសាងសង់។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយលើហេដ្ឋារចនាសម្ព័ន្ធដែលកំពុងដំណើរការ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃហេដ្ឋារចនាសម្ព័ន្ធដែលកំពុងដំណើរការដែលបានផ្ទេរទៅគណនីហេដ្ឋារចនាសម្ព័ន្ធ

**សមតុល្យ :** ឥណពេិក បង្ហាញតម្លៃហេដ្ឋារចនាសម្ព័ន្ធ ដែលកំពុងដំណើរការសាងសង់។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ផ្លូវថ្នល់ ផ្លូវទឹក (កំពុងដំណើរការ) (លេខ ២៣០៤១), ធារាសាស្ត្រ (កំពុងដំណើរការ) (លេខ ២៣០៤២), អាយស្ម័យយាន (កំពុងដំណើរការ) (លេខ ២៣០៤៣), អាកាសយានដ្ឋាន (កំពុងដំណើរការ) (លេខ ២៣០៤៤), ទូរគមនាគមន៍ (កំពុងដំណើរការ) (លេខ ២៣០៤៥), អគ្គិសនី (កំពុងដំណើរការ) (លេខ ២៣០៤៦), បណ្តាញបង្ហូរទឹក និងអនាម័យ (កំពុងដំណើរការ) (លេខ ២៣០៤៧) និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (កំពុងដំណើរការ) (លេខ ២៣០៤៨)។

**៨១-គណនី ផលិតកម្មបច្ចេកទេស សម្ភារ និងឧបករណ៍ (កំពុងដំណើរការ) " លេខ ២៣០៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រានូវតម្លៃផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍ ដែលកំពុងដំណើរការសាងសង់ ឬផលិត។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតម្លៃផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍ដែលកំពុងដំណើរការ

ឥណទាន : កត់ត្រាតម្លៃផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍ដែលកំពុងដំណើរការ ដែលបានផ្ទេរទៅគណនី ផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍ ដែលពាក់ព័ន្ធ

**សមតុល្យ :** ឥណពេិក បង្ហាញតម្លៃផលិតកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍ ដែលកំពុងដំណើរការ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ផលិតកម្មបច្ចេកទេស (កំពុងដំណើរការ) (លេខ ២៣០៥១), សម្ភារ (កំពុងដំណើរការ) (លេខ ២៣០៥២), គ្រឿងឧបករណ៍ (ហត្ថូបករណ៍) (កំពុងដំណើរការ) (លេខ ២៣០៥៣) និងសម្ភារផ្សេងៗ (កំពុងដំណើរការ) (លេខ ២៣០៥៨)។

**៨២-គណនី ការវិនិយោគក្នុងញាតិសម្ព័ន្ធនិងការវិនិយោគទុនរួមគ្នា " លេខ ២៦០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយវិនិយោគដោយចូលរួមជាមួយក្រុមហ៊ុន សហគ្រាស ស្ថាប័នហិរញ្ញវត្ថុ ក្នុងការអនុវត្តអាជីវកម្មរួមគ្នា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការវិនិយោគទុនរួមគ្នា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ទុនវិនិយោគដែលបានទទួលមកវិញ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានបន្ថយទុនវិនិយោគ

**សមតុល្យ :** ឥណពេិក បង្ហាញចំនួនទឹកប្រាក់ទុនវិនិយោគ ដែលកំពុងចូលរួម។

**ចំណាំ** :- គណនីនេះត្រូវចែកជាអនុគណនី ការវិនិយោគក្នុងញាតិសម្ព័ន្ធ (លេខ ២៦០១១), ការវិនិយោគទុនរួមគ្នា (លេខ ២៦០១២) និងការវិនិយោគក្នុងសហគ្រាសសាធារណៈ (លេខ ២៦០១៣)។

- ចំនួនទឹកប្រាក់ដែលកត់ត្រានៅក្នុងគណនីនេះគឺជាប្រាក់ដើមដែលបានចំណាយវិនិយោគ បានទទួលមកវិញ ឬ បន្ថយដើមទុនវិនិយោគ។

**៨៣-គណនី ការបែងចែកប្រាក់ចំណេញឬខាតនៃក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនដាក់ទុនរួមគ្នា "លេខ ២៦០២" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលពីការបែងចែកប្រាក់ចំណេញ ឬ ចំណាយលើការខាតបង់ ដែលត្រូវទទួល ឬ ត្រូវរ៉ាប់រង ពីការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនដាក់ទុនរួមគ្នា។

**ការកត់ត្រា:**

**ឥណពន្ធ** :- កត់ត្រាចំនួនទឹកប្រាក់ចំណូលពីការបែងចែកប្រាក់ចំណេញ ដែលត្រូវទទួល ដោយបដិភាគនឹងគណនី ចំណូលថវិកា

- កត់ត្រាចំនួនទឹកប្រាក់ខាតពីការវិនិយោគទុនរួមគ្នា ដែលបានកាត់បន្ថយទុនវិនិយោគរួមគ្នា ឬ ចំណាយប្រាក់សងការខាតបង់

**ឥណទាន** :- កត់ត្រាចំនួនទឹកប្រាក់ចំណេញដែលបានទទួលពីការបែងចែកប្រាក់ចំណេញ ដោយបដិភាគនឹងគណនីហិរញ្ញវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់ខាតពីការវិនិយោគទុនរួមគ្នា ដែលត្រូវរ៉ាប់រង ដោយបដិភាគនឹងគណនីចំណាយថវិកា

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណេញពីការវិនិយោគ ដែលត្រូវទទួល
ឥណទាយី បង្ហាញចំនួនទឹកប្រាក់ខាតពីការវិនិយោគ ដែលត្រូវដោះស្រាយ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី ការបែងចែកប្រាក់ចំណេញឬខាតនៃក្រុមហ៊ុនញាតិសម្ព័ន្ធ (លេខ ២៦០២១), ការបែងចែកប្រាក់ចំណេញឬខាតនៃក្រុមហ៊ុនដាក់ទុនរួមគ្នា (លេខ ២៦០២២) និងការបែងចែកប្រាក់ចំណេញ ឬ ខាតនៃសហគ្រាសសាធារណៈ (លេខ ២៦០២៣)។

**៨៤-គណនី ការឱ្យខ្ចី "លេខ ២៧០១" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ជាតិបានផ្តល់ទៅស្ថាប័ន គ្រឹះស្ថានសាធារណៈ សមូហភាពមូលដ្ឋាន ក្រុមហ៊ុន អង្គការ ខ្ចីដើម្បីបម្រើឱ្យទិសដៅវិនិយោគដោយមានការប្រាក់។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុន អង្គការ បានខ្ចី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមឱ្យខ្ចីដែលក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុន អង្គការ បានសងមកវិញ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដើមឱ្យខ្ចី ដែលពុំទាន់បានទូទាត់មកវិញ។

**ចំណាំ** :- គណនីនេះត្រូវចែកជាអនុគណនី ការឱ្យខ្ចីទៅសហគ្រាសសាធារណៈ (លេខ ២៧០១១), ការឱ្យខ្ចីទៅសហគ្រាសឯកជន (លេខ ២៧០១២), ការឱ្យខ្ចីទៅអង្គការមិនមែនរដ្ឋាភិបាល (លេខ ២៧០១៣) និងការឱ្យខ្ចីផ្សេងៗ (លេខ ២៧០១៤)។

- ការកត់ត្រានៅក្នុងគណនី ២៧០១ គឺតែចំនួនប្រាក់ដើមឱ្យខ្ចី និងបានសងមកវិញ រីឯកម្រៃការប្រាក់ដែលបានទទួលគឺត្រូវកត់ត្រាទៅក្នុងចំណូលថវិកាចរន្ត " គណនី ការប្រាក់នៃការឱ្យខ្ចី "។

**៨៥-អនុគណនី ប្រាក់តម្កល់ធានាបានបង់ "លេខ ២៧០២១" :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានបង់សម្រាប់តម្កល់ធានាលើសកម្មភាពផ្គត់ផ្គង់ និងសេវាកម្ម។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង់សម្រាប់តម្កល់ធានាសកម្មភាពផ្គត់ផ្គង់ សេវាកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានទូទាត់មកវិញ ឬ បានផ្ទេរទៅគណនីផ្សេងៗ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់តម្កល់ធានាបានបង់ ដែលពុំទាន់បានទូទាត់មកវិញ ឬ ពុំទាន់បានផ្ទេរ។

**ចំណាំ** : អនុគណនីនេះត្រូវតាមដានលម្អិតទៅតាមមុខសញ្ញាដែលបានបង់ប្រាក់តម្កល់ធានា។

**៨៦-អនុគណនី មូលបត្រ "លេខ ២៧០២២" :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការវិនិយោគលើមូលបត្ររយៈពេលវែង ជាមួយសហគ្រាស ក្រុមហ៊ុន ឬ ស្ថាប័នហិរញ្ញវត្ថុ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានវិនិយោគលើមូលបត្ររយៈពេលវែង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់មូលបត្រដែលបានលក់ ឬ ជម្រះ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានវិនិយោគលើមូលបត្ររយៈពេលវែង ដែលពុំទាន់បានជម្រះ ឬលក់ចេញ។

**ចំណាំ** : - អនុគណនីនេះត្រូវតាមដានលម្អិតទៅតាមប្រភេទមូលបត្រដែលបានវិនិយោគ។

- ចំនួនទឹកប្រាក់ដែលកត់ត្រាក្នុង អនុគណនីនេះគឺទាក់ទងតែនឹងប្រាក់ដើមតែប៉ុណ្ណោះ។

**៨៧-អនុគណនី អចលកម្មហិរញ្ញវត្ថុផ្សេងៗទៀត "លេខ ២៧០២៨" :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាតម្លៃអចលកម្មហិរញ្ញវត្ថុផ្សេងៗទៀត ក្រៅពីមូលបត្រ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មហិរញ្ញវត្ថុផ្សេងៗដែលបានវិនិយោគ

ឥណទាន : កត់ត្រាតម្លៃអចលកម្មរូបីដែលបានបន្ថយដោយលក់ ឬ ជម្រះ

**សមតុល្យ :** ឥណាយិក បង្ហាញតម្លៃអចលកម្មហិរញ្ញវត្ថុផ្សេងៗទៀត ដែលកំពុងមាន។

**៨៨-គណនី រំលស់អចលកម្មរូបី "លេខ ២៨០០" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបី។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានឱ្យដល់រំលស់អចលកម្មរូបី។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបី ដែលបានជម្រះជាមួយតម្លៃអចលកម្មរូបី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីក្នុងឆ្នាំ ដែលត្រូវបដិភាគជាមួយគណនីចំណាយថវិកា

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មរូបី បូកបន្ត។

**ចំណាំ** : - គណនីនេះត្រូវចែកជាអនុគណនី រំលស់សោហ៊ុយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ (លេខ ២៨០០៣) និងរំលស់ប្រកាសនីយបត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល (លេខ ២៨០០៥)។

- ការកត់ត្រាចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីរំលស់អចលកម្មរូបី យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ និងការផ្ទេរ។

- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្តនៃអចលកម្មស្មើនឹងតម្លៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់។ ការជម្រះអាចធ្វើទៅបាន លុះត្រាតែអចលកម្មនោះត្រូវបានឈប់ប្រើប្រាស់។

**៨៩-គណនី រំលស់ការកែលម្អ ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ "លេខ ២៨០២" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់លើការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានឱ្យដល់រំលស់អចលកម្មរូបី។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់ការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ ដែលបានជម្រះជាមួយតម្លៃអចលកម្មនៃការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់ការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗក្នុងឆ្នាំ ដែលត្រូវបដិភាគជាមួយគណនីចំណាយថវិកា

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់ការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ បូកបន្ត។

**ចំណាំ** : - គណនីនេះត្រូវចែកជាអនុគណនី វិលស់ការកែលម្អដីធ្លី (លេខ ២៨០២១), វិលស់ការកែលម្អដីរ៉ែ (២៨០២២) និងវិលស់ការកែលម្អសម្បត្តិធម្មជាតិផ្សេងៗ (លេខ ២៨០២៨)។

- ការកត់ត្រាចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីវិលស់ការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ យោងលើការផ្ទេរ ឬជម្រះ។
- ករណីដែលចំនួនទឹកប្រាក់វិលស់បូកបន្តនៃអចលកម្មស្មើនឹងតម្លៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានវិលស់។ ការជម្រះអាចធ្វើទៅបាន លុះត្រាតែអចលកម្មនោះត្រូវបានឈប់ប្រើប្រាស់។

**៩០-គណនី វិលស់សំណង់អគារ និងការកែលម្អ " លេខ ២៨០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់វិលស់សំណង់អគារ និងការកែលម្អអគារ។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានឱ្យដល់វិលស់អចលកម្មរូបី។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់វិលស់សំណង់អគារ និងការកែលម្អអគារ ដែលបានជម្រះជាមួយតម្លៃសំណង់អគារ និងការកែលម្អអគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់វិលស់សំណង់អគារ និងការកែលម្អអគារក្នុងឆ្នាំ ដែលត្រូវបដិភាគជាមួយគណនីចំណាយថវិកា

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់វិលស់សំណង់អគារនិងការកែលម្អ បូកបន្ត។

**ចំណាំ** : - គណនីនេះត្រូវចែកជាអនុគណនី វិលស់សំណង់អគារ (លេខ ២៨០៣១), វិលស់ការកែលម្អអគារ (លេខ ២៨០៣២) និងវិលស់សំណង់ផ្សេងៗ (លេខ ២៨០៣៨)។

- ការកត់ត្រាចំនួនទឹកប្រាក់ខាងឥណពន្ធនៃគណនីវិលស់អចលកម្មរូបី យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ ឬការផ្ទេរ។
- ករណីដែលចំនួនទឹកប្រាក់វិលស់បូកបន្តនៃអចលកម្មស្មើនឹងតម្លៃបញ្ចូល គឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានវិលស់។ ការជម្រះអាចធ្វើទៅបាន លុះត្រាតែអចលកម្មនោះត្រូវបានឈប់ប្រើប្រាស់។

**៩១-គណនី វិលស់ហេដ្ឋារចនាសម្ព័ន្ធ " លេខ ២៨០៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់វិលស់ហេដ្ឋារចនាសម្ព័ន្ធ។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានឱ្យដល់វិលស់អចលកម្មរូបី។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់វិលស់ហេដ្ឋារចនាសម្ព័ន្ធ ដែលបានជម្រះជាមួយតម្លៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់វិលស់ហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ ដែលត្រូវបដិភាគជាមួយគណនីចំណាយថវិកា

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់វិលស់ ហេដ្ឋារចនាសម្ព័ន្ធ បូកបន្ត។

**ចំណាំ** : - គណនីនេះត្រូវចែកជាអនុគណនី វិលស់ផ្លូវថ្នល់ ផ្លូវទឹក (លេខ ២៨០៤១), វិលស់ធារាសាស្ត្រ (លេខ ២៨០៤២), វិលស់អាយស្ម័យយាន (លេខ ២៨០៤៣), វិលស់អាកាសយានដ្ឋាន (២៨០៤៤), វិលស់បណ្តាញទូរគមនាគមន៍ (លេខ ២៨០៤៥), វិលស់បណ្តាញអគ្គិសនី (លេខ ២៨០៤៦), វិលស់បណ្តាញបង្ហូរទឹក និងអនាម័យ (លេខ ២៨០៤៧) និងវិលស់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (លេខ ២៨០៤៨)។

- ការកត់ត្រាចំនួនទឹកប្រាក់ខាងឥណពន្ធនៃគណនីវិលស់អចលកម្មរូបី យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ ឬការផ្ទេរ។
- ករណីដែលចំនួនទឹកប្រាក់វិលស់បូកបន្តនៃអចលកម្មស្មើនឹងតម្លៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានវិលស់។ ការជម្រះអាចធ្វើទៅបាន លុះត្រាតែអចលកម្មនោះត្រូវបានឈប់ប្រើប្រាស់។

**៩២-គណនី វិលស់ឋបនកម្មបច្ចេកទេស សម្ភារ និងបរិក្ខារ " លេខ ២៨០៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់វិលស់ឋបនកម្មបច្ចេកទេស សម្ភារ និងបរិក្ខារ។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានឱ្យដល់វិលស់អចលកម្មរូបី។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់ថបនកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍ ដែលបានជម្រះជាមួយតម្លៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីក្នុងឆ្នាំ ដែលត្រូវបដិភាគជាមួយគណនីចំណាយថវិកា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់ថបនកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍ ប្លុកបន្ត។

**ចំណាំ** :- គណនីនេះត្រូវបែកជាអនុគណនី រំលស់ថបនកម្មបច្ចេកទេស (លេខ ២៨០៥១), រំលស់សម្ភារ (លេខ ២៨០៥២), រំលស់គ្រឿងឧបករណ៍ (ហត្ថូបករណ៍) (លេខ ២៨០៥៣) និងរំលស់ផ្សេងៗ (លេខ ២៨០៥៨)។

- ការកត់ត្រាចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីរំលស់អចលកម្មរូបី យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ ឬការផ្ទេរ។
- ករណីដែលចំនួនទឹកប្រាក់រំលស់ប្លុកបន្តនៃអចលកម្មស្មើនឹងតម្លៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់។ ការជម្រះអាចធ្វើទៅបាន លុះត្រាតែអចលកម្មនោះត្រូវបានឈប់ប្រើប្រាស់។

**៩៣-គណនី រំលស់អចលកម្មរូបីផ្សេងទៀត " លេខ ២៨០៨ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីផ្សេងទៀត។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានរិលស់រំលស់អចលកម្មរូបី។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីផ្សេងៗ ដែលបានជម្រះជាមួយតម្លៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីផ្សេងៗក្នុងឆ្នាំ ដែលត្រូវបដិភាគជាមួយគណនីចំណាយថវិកា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មរូបីផ្សេងៗ ប្លុកបន្ត។

**ចំណាំ** :- គណនីនេះត្រូវបែកជាអនុគណនី រំលស់សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២៨០៨១), រំលស់សម្ភារឧបករណ៍ការិយាល័យ (លេខ ២៨០៨២), រំលស់សម្ភារ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ (លេខ ២៨០៨៣), រំលស់សង្ហារឹម (លេខ ២៨០៨៤) និងរំលស់អចលកម្មរូបីផ្សេងៗ (លេខ ២៨០៨៨)។

- ការកត់ត្រាចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីរំលស់អចលកម្មរូបីផ្សេងៗ យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ ការជម្រះ ឬ ការផ្ទេរ។
- ករណីដែលចំនួនទឹកប្រាក់រំលស់ប្លុកបន្តនៃអចលកម្មផ្សេងៗស្មើនឹងតម្លៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់។ ការជម្រះអាចធ្វើទៅបាន លុះត្រាតែអចលកម្មនោះត្រូវបានឈប់ប្រើប្រាស់។

**៩៤-គណនី រំលស់ទ្រព្យសម្បត្តិវិនិយោគរយៈពេលវែង " លេខ ២៨០៩ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់ទ្រព្យសម្បត្តិវិនិយោគរយៈពេលវែង។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានរិលស់រំលស់ទ្រព្យសម្បត្តិវិនិយោគ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់ទ្រព្យសម្បត្តិវិនិយោគ ដែលបានជម្រះជាមួយតម្លៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់ទ្រព្យសម្បត្តិវិនិយោគក្នុងឆ្នាំ ដែលត្រូវបដិភាគជាមួយគណនីចំណាយថវិកា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់ទ្រព្យសម្បត្តិវិនិយោគ ប្លុកបន្ត។

**ចំណាំ** :- ការកត់ត្រាចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីរំលស់ទ្រព្យសម្បត្តិវិនិយោគរយៈពេលវែង យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ ការជម្រះ ឬការផ្ទេរ។

- ករណីចំនួនទឹកប្រាក់រំលស់ប្លុកបន្តនៃទ្រព្យសម្បត្តិវិនិយោគស្មើនឹងតម្លៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់។ ការជម្រះអាចធ្វើទៅបាន លុះត្រាតែអចលកម្មនោះត្រូវបានឈប់ប្រើប្រាស់។

**៩៥-គណនី ទាយជ្ជទាន " លេខ ៣០០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ជាធនធាននៃតម្លៃអចលកម្មអរូបី អចលកម្មរូបី អចលកម្មហិរញ្ញវត្ថុ ដែលលក់ត្រូវសង

ប្រាក់បានឱ្យខ្ចី និងធនធានផ្សេងទៀត ដែលពុំទាន់បានកត់ត្រាទៅក្នុងលេខនាគណនេយ្យ។ តម្លៃនៃទ្រព្យសម្បត្តិ បំណុល ខ្ទង់ត្រូវទារទាំងនេះ គឺបានមកពីតារាងវាយតម្លៃនៅលើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ តារាងស្ថានភាពបំណុល និងតារាងស្ថានភាពទឹកប្រាក់ ត្រូវទាររបស់អង្គភាព ដែលមានការពាក់ព័ន្ធលើការគ្រប់គ្រងខ្ទង់ប្រាក់ទាំងនោះ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ខ្ចីដែលបានធ្វើសមាហរណកម្ម

- កត់ត្រាបន្ថយទឹកប្រាក់ខ្ចីដែលមានការភ័ន្តច្រឡំពេលធ្វើសមាហរណកម្ម ដោយប្រើសញ្ញាដក

ឥណទាន : - កត់ត្រាតម្លៃអចលកម្ម និងប្រាក់ឱ្យខ្ចីដែលបានធ្វើសមាហរណកម្ម

- កត់ត្រាបន្ថយចំនួនទឹកប្រាក់ការឱ្យខ្ចី និងចំនួនទឹកប្រាក់នៃតម្លៃអចលកម្មដែលបានធ្វើសមាហរណកម្មភ័ន្តច្រឡំ ដោយប្រើសញ្ញាដក
- កត់ត្រាចំនួនទឹកប្រាក់ដែលជាធនធាន ឬ ដែលបានផ្ទេរមកពីគណនីអកម្មផ្សេងទៀត

**សមតុល្យ :** ឥណទាយី បង្ហាញតំលៃអចលកម្ម ប្រាក់ឱ្យខ្ចី និងធនធានផ្សេងទៀត ដែលជាធនធានមានពីមុនមក។

### ៩៦-គណនី លំអៀងពីការវាយតម្លៃឡើងវិញអចលកម្ម " លេខ ៣០០២ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់លំអៀងដែលកើតមានពីការវាយតម្លៃឡើងវិញនូវអចលកម្មអរូបី និងរូបី ដោយយោងតាម គោលនយោបាយហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

**ការកត់ត្រា:**

ឥណពន្ធ : ពុំមានការកត់ត្រា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់លំអៀងរវាងតម្លៃថ្មីនិងតម្លៃបរិយាទានរបស់អចលកម្ម

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់លំអៀងពីការវាយតម្លៃឡើងវិញអចលកម្ម។

### ៩៧-គណនី កេរ្តិ៍មរតក និងអំណោយ " លេខ ៣០០៣ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ជាប្រភពធនធាននៃអចលកម្ម ដែលបានមកពីអំណោយ ឬកេរ្តិ៍មរតករបស់អ្នកដែលបាន ទទួលមរណៈភាព ឬ ម្ចាស់កម្មសិទ្ធិអចលកម្ម។

**ការកត់ត្រា:**

ឥណពន្ធ : ពុំមានប្រតិបត្តិការ

ឥណទាន : កត់ត្រាតម្លៃទ្រព្យសម្បត្តិ ដែលបានទទួលពីអំណោយ ឬពីកេរ្តិ៍មរតក។ ការកត់ត្រាដោយមានបដិភាគនឹងគណនី អចលកម្ម។

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃតម្លៃអចលកម្ម ដែលបានទទួលនិងចាត់ទុកជាធនធានរបស់រដ្ឋបាលឬអង្គភាពពាក់ព័ន្ធ។

### ៩៨-គណនី ចំណែកនៃអតិរេកថវិកាបានប្រើសម្រាប់ចំណាយវិនិយោគ " លេខ ៣០០៤ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃអតិរេកថវិកា ដែលបានប្រើប្រាស់សម្រាប់ចំណាយវិនិយោគ។

**ការកត់ត្រា:**

ឥណពន្ធ : ពុំមានប្រតិបត្តិការ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់អតិរេកដែលបានប្រើប្រាស់សម្រាប់ចំណាយវិនិយោគ ដោយកត់ត្រាបដិភាគនឹងគណនី យោងជាថ្មី

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃអតិរេកថវិកាដែលបានប្រើប្រាស់សម្រាប់ចំណាយវិនិយោគ ឬកបន្ត។

**<u>ចំណាំ</u>** : តួលេខចលនាខាងឥណទាន នៃគណនីចំណែកនៃអតិរេកថវិកាបានប្រើសម្រាប់ចំណាយវិនិយោគនេះ ស្មើនឹងតួលេខ នៃចំណាយវិនិយោគ (គណនីថ្នាក់២) ក្នុងឆ្នាំអនុវត្ត។

### ៩៩-គណនី យោងជាថ្មី " លេខ ៣១០១ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរមកពីគណនីលទ្ធផលនៃការិយបរិច្ឆេទ នៃការអនុវត្តថវិកា។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃលទ្ធផលឱនភាពដែលបានផ្ទេរមក

- កត់ត្រាចំនួនទឹកប្រាក់នៃអតិរេកថវិកាដែលបានប្រើសម្រាប់ចំណាយវិនិយោគ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃលទ្ធផលអតិរេកដែលបានផ្ទេរមក

**សមតុល្យ** : - ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ឱនភាពបូកបន្ត ដែលត្រូវយោងជាថ្មី

- ឥណទាយី បង្ហាញចំនួនទឹកប្រាក់អតិរេកបូកបន្ត ដែលត្រូវយោងជាថ្មី។

**ចំណាំ** : ការកត់ត្រាប្រតិបត្តិការជម្រះផ្ទេរលទ្ធផលពីគណនីលទ្ធផលនៃការិយបរិច្ឆេទមកគណនីយោងជាថ្មី គឺអនុវត្តនៅដើមឆ្នាំបន្ទាប់។

**១០០-គណនី លទ្ធផលនៃការិយបរិច្ឆេទ " លេខ ៣២០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាការគណនាលទ្ធផលនៃការិយបរិច្ឆេទនៃការអនុវត្តថវិកា ដោយផ្ទេរសមតុល្យចុងឆ្នាំនៃគណនី ចំណូល និងគណនីចំណាយថវិកាមកគណនីនេះ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាផ្ទេរសមតុល្យឥណពន្ធនៃគណនី ចំណាយថវិកា (គណនីថ្នាក់ ៦)

- កត់ត្រាផ្ទេរលទ្ធផលអតិរេកចូលគណនី យោងជាថ្មី

- កត់ត្រាផ្ទេរលទ្ធផលអតិរេករបស់រតនាគាររាជធានី ខេត្ត ទៅរតនាគារកណ្តាល (កត់ត្រានៅរតនាគាររាជធានី ខេត្ត)

- កត់ត្រាផ្ទេរលទ្ធផលឱនភាពពីរតនាគាររាជធានី ខេត្ត មករតនាគារកណ្តាល (កត់ត្រានៅរតនាគារកណ្តាល)

ឥណទាន : - កត់ត្រាផ្ទេរសមតុល្យឥណទាយីនៃគណនី ចំណូលថវិកា (គណនីថ្នាក់ ៧)

- កត់ត្រាផ្ទេរលទ្ធផលឱនភាពចូលគណនី យោងជាថ្មី

- កត់ត្រាផ្ទេរលទ្ធផលឱនភាពរបស់រតនាគាររាជធានី ខេត្ត ទៅរតនាគារកណ្តាល (កត់ត្រានៅរតនាគាររាជធានី ខេត្ត)

- កត់ត្រាផ្ទេរលទ្ធផលអតិរេកពីរតនាគាររាជធានី ខេត្ត មករតនាគារកណ្តាល (កត់ត្រានៅរតនាគារកណ្តាល)

**សមតុល្យ** : - ឥណទាយី បង្ហាញលទ្ធផល អតិរេកនៃការអនុវត្តថវិកា ដែលពុំទាន់បានចាត់ចែង

-ឥណពន្ធ បង្ហាញលទ្ធផល ឱនភាពនៃការអនុវត្តថវិកា ដែលពុំទាន់បានចាត់ចែង។

**ចំណាំ** : - ចំពោះថវិកាជាតិនៅរាជធានី ខេត្ត គណនីនេះត្រូវអស់សមតុល្យ នៅក្រោយពេលផ្ទេរមករតនាគារកណ្តាល។

- ចំពោះថវិការាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពប្រហាក់ប្រហែលសមតុល្យនៃគណនីនេះត្រូវយោងទៅឆ្នាំបន្ទាប់ រួចផ្ទេរទៅគណនីយោងជាថ្មី។

**១០១-គណនី អ្នកផ្គត់ផ្គង់ " លេខ ៤០០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់ទំនិញ អចលកម្ម អ្នកផ្តល់សេវាកម្ម និងការងារ ដោយយោងតាមអាណត្តិបើកប្រាក់ ឬ ការបង្វែរមកពីប្រភពផ្សេងៗ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនអត្ថគាហកៈ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុក ផ្ទេរចូលថវិការដ្ឋ ឬ ទូទាត់ទៅមុខសញ្ញាផ្សេង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ទំនិញ អចលកម្ម សេវាកម្ម ការងារ តាមរយៈអាណត្តិបើកប្រាក់ ឬបង្វែរពីគណនីផ្សេងៗ

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់។

**ចំណាំ** : - គណនីនេះពុំចាំបាច់មានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអ្នកផ្គត់ផ្គង់នីមួយៗ។

- គណនីនេះត្រូវតាមដានលម្អិតជាប្រាក់រៀល និងប្រាក់រូបិយប័ណ្ណបរទេស ករណីបើមាន។

**១០២-គណនី ប្រាក់ដើម ការប្រាក់ និងវិភាគទានត្រូវសង “ លេខ ៤០០២ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងប្រាក់ដើម ការប្រាក់ខ្ចី និងវិភាគទានដល់បណ្ដាប្រទេសនានា អង្គការជាតិ អង្គការអន្តរជាតិ និងសមាគមន៍ ដោយយោងតាមអាណត្តិបើកប្រាក់ ឬ លិខិតផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅអ្នកឱ្យខ្ចី (ប្រាក់ដើម ការប្រាក់)

- កត់ត្រាចំនួនទឹកប្រាក់ដែលបានបន្ថយ លុបចោលបំណុល ការប្រាក់ ឬ វិភាគទាន

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បំណុលនៃការខ្ចី ឬ ការប្រាក់ ឬ វិភាគទានដែលត្រូវសង

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកឱ្យខ្ចីប្រាក់។

<u>**ចំណាំ**</u> : - គណនីនេះពុំចាំបាច់មានតំរូវហត្ថលេខារបស់ម្ចាស់គណនីទេ។

- គណនីនេះត្រូវតាមដានលម្អិតជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកព្រមគ្នា។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គភាពដែលទទួលការទូទាត់សងនីមួយៗ។

**១០៣-គណនី ការកាត់ទុក ការជំនាស់ “ លេខ ៤០០៣ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុក ក្រៅពីប្រាក់ពន្ធសម្រាប់សងទៅមុខសញ្ញាផ្សេងៗ ដោយយោងតាមការសម្រេចរបស់តុលាការ ឬអាជ្ញាធរដែលមានសមត្ថកិច្ច។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅអ្នកទទួលផលពីការកាត់ទុកក្រោមរូបភាពជាសាច់ប្រាក់ ឬ បង្វែរ ឬជាមូលប្បទានបត្រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ចេញពីចំនួនទឹកប្រាក់ដែលត្រូវទូទាត់ជូនទៅអ្នកផ្គត់ផ្គង់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលបានកាត់ទុក ហើយពុំទាន់បានសងទៅអ្នកទទួលផល។

<u>**ចំណាំ**</u> : - គណនីនេះពុំចាំបាច់មានតំរូវហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអ្នកទទួលផលបានពីការកាត់ទុក។

**១០៤-គណនី ការកាត់ទុកប្រាក់ពន្ធរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល “ លេខ ៤០០៤ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ពន្ធដែលគ្រឹះស្ថានសាធារណៈរដ្ឋបាល បានកាត់ទុកពីអ្នកផ្គត់ផ្គង់ មន្ត្រីរាជការ និងបុគ្គលិក។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅអង្គភាពទទួលផលពីការកាត់ទុកក្រោមរូបភាពបង្វែរ ឬជាមូលប្បទានបត្រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ពន្ធដែលបានកាត់ចេញពីចំនួនទឹកប្រាក់ត្រូវទូទាត់ជូនអ្នកផ្គត់ផ្គង់ មន្ត្រីរាជការ និងបុគ្គលិក

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ពន្ធដែលបានកាត់ទុក ហើយពុំទាន់បានសងទៅអង្គភាពទទួលផលពីការកាត់ទុក។

**១០៥-គណនី ប័ណ្ណរតនាគារ “ លេខ ៤១០១ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការបោះផ្សាយលក់ប័ណ្ណរតនាគារ និងបានសងប្រាក់ទៅបរិវិសករប័ណ្ណរតនាគារវិញ តាមកាលវសាន្ត។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅបរិវិសករប័ណ្ណរតនាគារតាមតម្លៃចារឹក ជាសាច់ប្រាក់ ឬបង្វែរ ឬមូលប្បទានបត្រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅបរិវិសករប័ណ្ណរតនាគារ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលពុំទាន់បានសងទៅបរិវិសករប័ណ្ណរតនាគារ។

<u>**ចំណាំ**</u> : គណនីនេះត្រូវតាមដានលម្អិតទៅតាមប្រភេទប័ណ្ណរតនាគារនីមួយៗ។

**១០៦-គណនី ការខ្ចីពីទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លីផ្សេងៗ “ លេខ ៤១០៨ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការខ្ចីពីទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លីផ្សេងៗ ក្រៅពីការខ្ចីតាមរយៈប័ណ្ណរតនាគារ។

**ការកត់ត្រា៖**

ឥណពន្ធ ៖ កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅម្ចាស់បំណុលលើការខ្ចីពីទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លីផ្សេងៗ

ឥណទាន ៖ កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅម្ចាស់បំណុលលើការខ្ចីពីទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លីផ្សេងៗ

**សមតុល្យ ៖** ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលពុំទាន់បានសងលើការខ្ចីពីទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លីផ្សេងៗ។

**ចំណាំ** ៖ គណនីនេះត្រូវបើកលម្អិតទៅតាមប្រភពដែលបានទទួលប្រាក់ខ្ចី។

**១០៧-គណនី ប្រាក់បៀវត្សនិងលាភការត្រូវសង " លេខ ៤២០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បៀវត្ស លាភការ រង្វាន់ ប្រាក់វិភាជន៍សង្គម និងប្រាក់បំណាច់ផ្សេងៗ ដែលត្រូវសង ទៅ អំណាចសាធារណ សមាជិកក្រុមប្រឹក្សាភិបាល គណៈអភិបាល បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍ និងបុគ្គលិកមិនមែនក្របខណ្ឌ ដោយយោងតាម អាណត្តិបើកប្រាក់ ឬ លិខិតស្នើសុំរបស់អង្គភាពសាមី។

**ការកត់ត្រា៖**

ឥណពន្ធ ៖ - កត់ត្រាចំនួនទឹកប្រាក់បៀវត្សនិងលាភការដែលបានបើកផ្តល់

- កត់ត្រាចំនួនទឹកប្រាក់បៀវត្សនិងលាភការដែលបានកាត់ទុកសងទៅមុខសញ្ញាផ្សេង (ក្រៅពីប្រាក់ពន្ធ)

ឥណទាន ៖ កត់ត្រាចំនួនទឹកប្រាក់បៀវត្សនិងលាភការដែលត្រូវសង

**សមតុល្យ ៖** ឥណទាយី បង្ហាញចំនួនទឹកប្រាក់បៀវត្សនិងលាភការ ដែលពុំទាន់បានបើកផ្តល់ ។

**ចំណាំ** ៖ - គណនីនេះមានគំរូហត្ថលេខារបស់ម្ចាស់គណនីដែលជាភ្នាក់ងារបើកផ្តល់។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គភាពនីមួយៗ។
- ក្នុងការជម្រះបុរេប្រទានសម្រាប់ប្រាក់បៀវត្សនិងលាភការ គឺត្រូវឆ្លងកាត់គណនីលេខ៤២០១។

**១០៨-គណនី សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗត្រូវសង " លេខ ៤២០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្មនិងសោហ៊ុយផ្សេងៗ ដែលត្រូវសងទៅអំណាចសាធារណៈ សមាជិក ក្រុមប្រឹក្សាភិបាល គណៈអភិបាល បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍ និងបុគ្គលិកមិនមែនក្របខណ្ឌ។

**ការកត់ត្រា៖**

ឥណពន្ធ ៖ កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្មនិងសោហ៊ុយផ្សេងៗដែលបានបើកផ្តល់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ ដោយបង្វែរ

ឥណទាន ៖ កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្មនិងសោហ៊ុយផ្សេងៗដែលត្រូវបើកផ្តល់

**សមតុល្យ ៖** ឥណទាយី បង្ហាញចំនួនទឹកប្រាក់សោហ៊ុយបេសកកម្មនិងសោហ៊ុយផ្សេងៗដែលត្រូវសង។

**ចំណាំ** ៖ - គណនីនេះពុំចាំបាច់មានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គភាពនីមួយៗ។

**១០៩-គណនី ទំនាក់ទំនង ផ្ទេរសាច់ប្រាក់ " លេខ ៤៣០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនសាច់ប្រាក់ដែលរតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត បានផ្ទេរទៅនិងទទួល តាមរយៈ ធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជដៃគូ។

**ការកត់ត្រា៖**

ឥណពន្ធ ៖ - កត់ត្រាចំនួនសាច់ប្រាក់ដែលរតនាគារថ្នាក់កណ្តាលបានផ្ទេរទៅរតនាគាររាជធានី ខេត្ត (ការកត់ត្រានៅរតនាគារថ្នាក់ កណ្តាល ក្រោយពីបានទទួលប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត)

- កត់ត្រាចំនួនសាច់ប្រាក់ដែលរតនាគាររាជធានី ខេត្តបានផ្ទេរទៅរតនាគារកណ្តាល (ការកត់ត្រានៅរតនាគារ រាជធានី ខេត្ត ក្រោយពីទទួលបានប្រកាសឥណពន្ធពីសាខាធនាគារ) ហើយរតនាគាររាជធានី ខេត្តត្រូវរៀបចំប្រកាសឥណពន្ធផ្ញើទៅ រតនាគារកណ្តាល
- កត់ត្រាផ្ទេរសមតុល្យឥណទាយី ទៅគណនី ទំនាក់ទំនង ផ្ទេរសមតុល្យ

ឥណទាន : - កត់ត្រាចំនួនសាច់ប្រាក់ដែលធនាគារថ្នាក់កណ្តាលបានទទួលពីធនាគាររាជធានី ខេត្ត (ការកត់ត្រានៅធនាគារថ្នាក់កណ្តាល ក្រោយពីបានទទួលប្រកាសឥណពន្ធរបស់ធនាគាររាជធានី ខេត្ត)

- កត់ត្រាចំនួនសាច់ប្រាក់ដែលធនាគាររាជធានី ខេត្តបានទទួលពីធនាគារថ្នាក់កណ្តាល (ការកត់ត្រានៅធនាគាររាជធានី ខេត្ត ក្រោយពីបានទទួលប្រកាសឥណទានពីសាខាធនាគារ) ហើយធនាគាររាជធានី ខេត្តត្រូវរៀបចំប្រកាសឥណទានផ្ញើទៅធនាគារកណ្តាល

- កត់ត្រាផ្ទេរសមតុល្យឥណាយិក ទៅគណនី ទំនាក់ទំនង ផ្ទេរសមតុល្យ

សមតុល្យ : - ឥណាយិក បង្ហាញសមតុល្យពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនង ផ្ទេរសមតុល្យ (នៅធនាគារថ្នាក់កណ្តាលនិងធនាគាររាជធានី ខេត្ត)

- ឥណទាយី បង្ហាញសមតុល្យពុំទាន់បានផ្ទេរទៅគណនី ទំនាក់ទំនង ផ្ទេរសមតុល្យ (នៅធនាគារថ្នាក់កណ្តាល និងធនាគាររាជធានី ខេត្ត)។

<u>**ចំណាំ**</u> : - គណនីនេះត្រូវអសមតុល្យនៅដំណាច់ឆ្នាំ។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមធនាគារថ្នាក់កណ្តាល និងធនាគាររាជធានី ខេត្តនីមួយៗ។

**១១០-គណនី ទំនាក់ទំនង ផ្ទេរប្រតិបត្តិការ " លេខ ៤៣០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាតួលេខផ្ទេរប្រតិបត្តិការពីធនាគារថ្នាក់កណ្តាលទៅធនាគាររាជធានី ខេត្ត និងផ្ទុយមកវិញ ដោយយោងតាមប្រកាសឥណពន្ធ និងប្រកាសឥណទានរបស់ធនាគារ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាតួលេខផ្ទេរប្រតិបត្តិការពីធនាគាររាជធានី ខេត្តមកធនាគារកណ្តាល (ការកត់ត្រានៅធនាគារថ្នាក់កណ្តាល ដោយយោងតាមប្រកាសឥណទានរបស់ធនាគាររាជធានី ខេត្ត)

- កត់ត្រាតួលេខផ្ទេរប្រតិបត្តិការពីធនាគារកណ្តាលមកធនាគាររាជធានី ខេត្ត (ការកត់ត្រានៅធនាគាររាជធានី ខេត្ត ដោយយោងតាមប្រកាសឥណទានរបស់ធនាគារកណ្តាល)

- កត់ត្រាផ្ទេរសមតុល្យឥណទាយី ទៅគណនីទំនាក់ទំនងផ្ទេរសមតុល្យ

ឥណទាន : - កត់ត្រាតួលេខផ្ទេរប្រតិបត្តិការពីធនាគារថ្នាក់កណ្តាលទៅធនាគាររាជធានី ខេត្ត (ការកត់ត្រានៅធនាគារថ្នាក់កណ្តាល ដោយយោងតាមប្រកាសឥណទានរបស់ធនាគារកណ្តាល)

- កត់ត្រាតួលេខផ្ទេរប្រតិបត្តិការពីធនាគាររាជធានី ខេត្តទៅធនាគារកណ្តាល (ការកត់ត្រានៅធនាគាររាជធានី ខេត្ត ដោយយោងតាមប្រកាសឥណទានរបស់ធនាគាររាជធានី ខេត្ត)

- កត់ត្រាផ្ទេរសមតុល្យឥណាយិក ទៅគណនីទំនាក់ទំនងផ្ទេរសមតុល្យ

សមតុល្យ : - ឥណាយិក បង្ហាញសមតុល្យដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនងផ្ទេរសមតុល្យ (នៅធនាគារថ្នាក់កណ្តាល និងធនាគាររាជធានី ខេត្ត)

- ឥណទាយី បង្ហាញសមតុល្យដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនងផ្ទេរសមតុល្យ (នៅធនាគារថ្នាក់កណ្តាល និងធនាគាររាជធានី ខេត្ត)។

<u>**ចំណាំ**</u> : - គណនីនេះត្រូវអសមតុល្យក្រោយពីធ្វើការផ្ទៀងផ្ទាត់រវាងធនាគារថ្នាក់កណ្តាលនិងធនាគាររាជធានី ខេត្ត។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមធនាគារកណ្តាលនិងធនាគាររាជធានី ខេត្ត។

**១១១-គណនី ទំនាក់ទំនង ផ្ទេរសមតុល្យ " លេខ ៤៣០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាតួលេខផ្ទេរសមតុល្យរបស់គណនីទំនាក់ទំនងផ្ទេរសាច់ប្រាក់និងផ្ទេរប្រតិបត្តិការមកគណនីនេះ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាតួលេខផ្ទេរសមតុល្យឥណាយិកពីគណនីទំនាក់ទំនងផ្ទេរសាច់ប្រាក់ (កត់ត្រានៅធនាគាររាជធានី ខេត្ត និងនៅធនាគារថ្នាក់កណ្តាល)

- កត់ត្រាតួលេខផ្ទេរសមតុល្យឥណាយិកពីគណនីទំនាក់ទំនងផ្ទេរប្រតិបត្តិការ (កត់ត្រានៅធនាគារថ្នាក់កណ្តាល និងនៅធនាគាររាជធានី ខេត្ត)

ឥណទាន  : - កត់ត្រាតួលេខផ្ទេរសមតុល្យឥណទាយីពីគណនីទំនាក់ទំនងផ្ទេរសាច់ប្រាក់ (កត់ត្រានៅរតនាគារថ្នាក់កណ្តាលនិងនៅរតនាគាររាជធានីខេត្ត)

- កត់ត្រាតួលេខផ្ទេរសមតុល្យឥណទាយីពីគណនីទំនាក់ទំនងផ្ទេរប្រតិបត្តិការ (កត់ត្រានៅរតនាគារថ្នាក់កណ្តាលនិងនៅរតនាគាររាជធានី ខេត្ត)

**សមតុល្យ** : - ឥណាយិក បង្ហាញតួលេខបូកបន្តនៃប្រតិបត្តិការផ្ទេរសាច់ប្រាក់ និងប្រតិបត្តិការផ្ទេរប្រតិបត្តិការ ដែលកើតមាននៅរតនាគាររាជធានី ខេត្ត និងនៅរតនាគារថ្នាក់កណ្តាល

- ឥណទាយី បង្ហាញតួលេខបូកបន្តនៃប្រតិបត្តិការផ្ទេរសាច់ប្រាក់ និងប្រតិបត្តិការផ្ទេរប្រតិបត្តិការ ដែលកើតមាននៅរតនាគាររាជធានី ខេត្ត និងនៅរតនាគារថ្នាក់កណ្តាល។

<u>**ចំណាំ**</u> : - សមតុល្យឥណាយិក នៅរតនាគារថ្នាក់កណ្តាលឆ្លុះបញ្ចាំងបញ្ច្រាសនិងសមតុល្យឥណទាយីនៅរតនាគាររាជធានី ខេត្ត។

- សមតុល្យឥណទាយី នៅរតនាគារថ្នាក់កណ្តាលឆ្លុះបញ្ចាំងបញ្ច្រាសនិងសមតុល្យឥណាយិកនៅរតនាគាររាជធានី ខេត្ត។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមរតនាគារថ្នាក់កណ្តាលនិងរតនាគាររាជធានី ខេត្ត។

**១១២-គណនី ទំនាក់ទំនងផ្ទៃក្នុង ប្រព័ន្ធព័ត៌មានវិទ្យា " លេខ ៤៣០៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាដោយស្វ័យប្រវត្តិនូវតួលេខនៃប្រតិបត្តិការផ្សេងៗដែលកើតមានឡើងនៅពេលឆ្លងចំណាត់ថ្នាក់អង្គភាពប្រតិបត្តិក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការកត់ត្រាខាងឥណពន្ធទន្ទឹមនឹងខាងឥណទាន ហើយត្រូវអសមតុល្យនៅពេលប្រតិបត្តិការត្រូវបានបញ្ចប់។

<u>**ចំណាំ**</u> : - គណនីលេខ ៤៣០៥ ជាប្រភេទគណនីចម្លងក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- គណនីនេះមិនត្រូវបានបង្ហាញនៅក្នុងតារាងតុល្យភាពគណនីទេ។

**១១៣-គណនី ប្រាក់បញ្ញើរបស់ថវិកាឧបសម្ព័ន្ធ " លេខ ៤៤០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់អង្គភាពដែលជាអ្នកអនុវត្តថវិកាឧបសម្ព័ន្ធ ដែលប្រភពចំណូលនិងចំណាយត្រូវបានកំណត់ដោយក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ក្រោមជាតិ ជាអ្នកគ្រប់គ្រង និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណាយរបស់អង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយរបស់អង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ ដែលបានផ្ទេរចូលជាចំណូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលរបស់អង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធដែលបានបង់ចូលជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬ ដោយបង្វែរ ឬ អាណត្តិបើកប្រាក់

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើថវិកាឧបសម្ព័ន្ធរបស់អង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ ដែលកំពុងមាននៅរតនាគារ ហើយពុំទាន់បានប្រើប្រាស់។

<u>**ចំណាំ**</u> : - គណនីនេះមានប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើរបស់ថវិកាឧបសម្ព័ន្ធនៅរតនាគារ មានលេខសម្គាល់ ១២០១។

- គណនីនេះត្រូវមានតំរូវហត្ថលេខានិងតាមដានលម្អិតទៅតាមអង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធនីមួយៗ។

**១១៤-គណនី ប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត " លេខ ៤៤០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត ដែលបានពីប្រភពចំណូលផ្ទាល់នៅរាជធានីខេត្ត ឧបត្ថម្ភធនពីរដ្ឋ ចំណូលពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលរាជធានី ខេត្ត បានចំណាយជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ

- កត់ត្រាចំនួនទឹកប្រាក់ដែលរាជធានី ខេត្ត បានផ្ទេរចូលថវិការដ្ឋ (ផ្ទេរអតិរេក) ឬ បង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលរាជធានី ខេត្ត បានទទួលជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ

- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភធន ដែលបានទទួលពីរដ្ឋ ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗ

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត ដែលកំពុងមាននៅរតនាគារ ហើយពុំទាន់បានប្រើប្រាស់។

**ចំណាំ** : - គណនីនេះមានប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្តនៅរតនាគារ មានលេខសម្គាល់ ១២០២។
- គណនីនេះត្រូវមានគំរូហត្ថលេខាម្ចាស់គណនី។

**១១៥-គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ " លេខ ៤៤០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានពីប្រភពចំណូលផ្ទាល់ ពីថវិការាជធានី ខេត្ត ឧបត្ថម្ភធនពីរដ្ឋ ចំណូលពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលក្រុង ស្រុក ខណ្ឌ បានចំណាយជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ដែលក្រុង ស្រុក ខណ្ឌ បានផ្ទេរចូលថវិការាជធានី ខេត្ត ឬថវិការដ្ឋ (ផ្ទេរអតិរេក) ឬបង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលក្រុង ស្រុក ខណ្ឌ បានទទួលជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភធន ដែលបានទទួលពីរដ្ឋ ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗ

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ ដែលកំពុងមាននៅរតនាគារ ហើយពុំទាន់បានប្រើប្រាស់។

**ចំណាំ** : - គណនីនេះត្រូវមានគំរូហត្ថលេខាម្ចាស់គណនីនិងតាមដានលម្អិតទៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗ។
- គណនីនេះមានប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌនៅរតនាគារ ដែលមានលេខសម្គាល់ ១២០៣។

**១១៦-គណនី ប្រាក់បញ្ញើថវិការបស់ឃុំ សង្កាត់ " លេខ ៤៤០៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលឃុំ សង្កាត់ ដែលបានពីប្រភពចំណូលផ្ទាល់ ឧបត្ថម្ភធនពីរដ្ឋ ឧបត្ថម្ភធនពីរាជធានី ខេត្ត ឧបត្ថម្ភធនពីក្រុង ស្រុក ខណ្ឌ ចំណូលពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលឃុំ សង្កាត់ បានចំណាយជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ដែលឃុំ សង្កាត់ បានបង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលឃុំ សង្កាត់បានទទួលជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភធន ដែលបានទទួលពីរដ្ឋ ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើថវិការបស់ឃុំ សង្កាត់ ដែលកំពុងមាន ហើយពុំទាន់បានប្រើប្រាស់។

**ចំណាំ** : - គណនីនេះត្រូវមានគំរូហត្ថលេខាម្ចាស់គណនី និងតាមដានលម្អិតទៅតាមឃុំ សង្កាត់នីមួយៗ។
- គណនីនេះមានប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នៅរតនាគារ ដែលមានលេខសម្គាល់ ១២០៤។

**១១៧-គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល " លេខ ៤៤០៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលបានពីប្រភពចំណូលផ្ទាល់ ឧបត្ថម្ភធនពីក្រសួងអាណាព្យាបាល ចំណូលពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលបានចំណាយជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលបានបង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលបានទទួលជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភធន ដែលបានទទួលពីរដ្ឋ ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលកំពុងមាននៅរតនាគារ ហើយពុំទាន់បានប្រើប្រាស់។

**ចំណាំ** : - គណនីនេះមានប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ ដែលមានលេខសម្គាល់ ១២០៥។

- គណនីនេះត្រូវមានគំរូហត្ថលេខាម្ចាស់គណនី និងតាមដានលម្អិតទៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ។
- គណនីនេះត្រូវចែកជា អនុគណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រាក់រៀល (លេខ ៤៤០៥១) និង ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រាក់ដុល្លារអាមេរិក (លេខ ៤៤០៥២)។

**១១៨-គណនី ប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ "លេខ ៤៤០៦" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់សហគ្រាសសាធារណៈ ដែលមានប្រភពចំណូលផ្ទាល់ ឧបត្ថម្ភធនពីរដ្ឋ និងពីប្រភពចំណូលផ្សេងទៀត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលសហគ្រាសសាធារណៈបានចំណាយជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ដែលសហគ្រាសសាធារណៈរដ្ឋបាលបានបង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលសហគ្រាសសាធារណៈបានទទួលជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភធន ដែលបានទទួលពីរដ្ឋ និងពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ ដែលកំពុងមាននៅរតនាគារ ហើយពុំទាន់ប្រើប្រាស់។

**<u>ចំណាំ</u>** : - គណនីនេះត្រូវចែកជាអនុគណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច (លេខ ៤៤០៦១), ប្រាក់បញ្ញើរបស់ក្រុមហ៊ុនរដ្ឋ (លេខ ៤៤០៦២) និងប្រាក់បញ្ញើរបស់ក្រុមហ៊ុនចម្រុះ (លេខ ៤៤០៦៣)។
- គណនីនេះត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។
- គណនីនេះត្រូវតាមដានលម្អិតទៅតាមសហគ្រាសសាធារណៈនីមួយៗ។

**១១៩-គណនី ប្រាក់បញ្ញើរបស់ក្រសួង មន្ទីរ និងអង្គភាពចំណុះ "លេខ ៤៤០៧" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់ក្រសួង មន្ទីរ និងអង្គភាពចំណុះក្រសួង មន្ទីរ (ក្រៅពីប្រាក់បៀវត្ស ប្រាក់បំណាច់ រង្វាន់ទេយ្យបុរេប្រទាន រង្វាន់ទេយ្យចំណូល ប្រាក់បេសកកម្ម និងសោហ៊ុយផ្សេងៗ)។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់ដែលបានបង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលក្រសួង មន្ទីរ និងអង្គភាពចំណុះបានទទួលដោយអាណត្តិបើកប្រាក់ ឬ ពីប្រភពផ្សេងមក និងប្រាក់បុរេប្រទាន
- កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលក្រសួង មន្ទីរ និងអង្គភាពចំណុះបានបង់ចូលរតនាគារជាសាច់ប្រាក់ ឬដោយបង្វែរ ឬជាមូលប្បទានបត្រ

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ក្រសួង មន្ទីរ និងអង្គភាពចំណុះ ដែលកំពុងមាននៅរតនាគារ ហើយពុំទាន់បានប្រើប្រាស់។

**<u>ចំណាំ</u>** : - គណនីនេះត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។
- គណនីនេះត្រូវចែកជាអនុគណនី ប្រាក់បញ្ញើរបស់ក្រសួង (លេខ ៤៤០៧១), ប្រាក់បញ្ញើរបស់អង្គភាពចំណុះក្រសួង (លេខ ៤៤០៧២), ប្រាក់បញ្ញើរបស់មន្ទីរ (លេខ ៤៤០៧៣) និងប្រាក់បញ្ញើរបស់អង្គភាពចំណុះមន្ទីរ (លេខ ៤៤០៧៤)។
- គណនីនេះត្រូវតាមដានលម្អិតទៅតាមក្រសួង មន្ទីរ និងអង្គភាពចំណុះនីមួយៗ។

**១២០-គណនី មូលនិធិក្រុង ស្រុក "លេខ ៤៤០៨" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយមូលនិធិដែលបានមកពីឧបត្ថម្ភធនពីថវិការដ្ឋ អំណោយ អង្គការជាតិ អន្តរជាតិ និងពីប្រភពផ្សេងទៀត ដែលផ្តល់ឱ្យក្រុង ស្រុក។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង្វែរទៅថវិកាក្រុង ស្រុក និងមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានពីឧបត្ថម្ភធនពីថវិការដ្ឋ ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់មូលនិធិក្រុង ស្រុក ដែលមាននៅរតនាគារកណ្តាល ហើយពុំទាន់បានបែងចែក។

<u>**ចំណាំ**</u> : - គណនីនេះត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។

- សមតុល្យនៃគណនីនេះត្រូវយោងទៅការិយបរិច្ឆេទបន្ទាប់។

**១២១-គណនី មូលនិធិឃុំ សង្កាត់ " លេខ ៤៤០៩ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយមូលនិធិដែលបានមកពីឧបត្ថម្ភធនពីថវិការដ្ឋ អំណោយ អង្គការជាតិ អន្តរជាតិ និងពីប្រភពផ្សេងទៀត សម្រាប់ផ្តល់ឱ្យឃុំ សង្កាត់។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង្វែរទៅថវិកាឃុំ សង្កាត់ និងមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានពីឧបត្ថម្ភធនពីថវិការដ្ឋ ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់មូលនិធិឃុំ សង្កាត់ ដែលមាននៅរតនាគារកណ្តាល ហើយពុំទាន់បានបែងចែក។

<u>**ចំណាំ**</u> : - គណនីនេះ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។

- សមតុល្យនៃគណនីនេះត្រូវយោងទៅការិយបរិច្ឆេទបន្ទាប់។

**១២២-គណនី មូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត " លេខ ៤៤១០ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយឧបត្ថម្ភធនផ្តល់ដោយថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងប្រភពផ្សេងទៀត សម្រាប់ផ្តល់ឱ្យរាជធានី ខេត្ត។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយពីមូលនិធិដោយផ្ទេរទៅរដ្ឋបាលរាជធានី ខេត្ត ឬមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានពីឧបត្ថម្ភធនពីថវិការដ្ឋបាលរាជធានី ខេត្ត និងពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់មូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត ដែលពុំទាន់បានបែងចែក។

<u>**ចំណាំ**</u> : - គណនីនេះ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។ សមតុល្យនៃគណនីនេះត្រូវយោងទៅការិយបរិច្ឆេទបន្ទាប់។

- ការផ្ទេរប្រាក់ពីគណនីនេះត្រូវមានលិខិតសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**១២៣-គណនី មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ " លេខ ៤៤១១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយឧបត្ថម្ភធនផ្តល់ដោយថវិការដ្ឋ ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយពីមូលនិធិជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយពីមូលនិធិដោយផ្ទេរទៅរដ្ឋបាលរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានពីឧបត្ថម្ភធនពីថវិការដ្ឋ ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពុំទាន់បានបែងចែក។

<u>**ចំណាំ**</u> : - គណនីនេះត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។

- សមតុល្យនៃគណនីនេះត្រូវយោងទៅការិយបរិច្ឆេទបន្ទាប់។

- គណនីនេះមានប្រតិបត្តិការបញ្ចូលនៃគណនីប្រាក់បញ្ញើរូបនិធិវិនិយោគនៅអគ្គនាគារ ដែលមានលេខសម្គាល់ ៧២៦៧។

**១២៤-គណនី ប្រាក់បញ្ញើរបស់ក្រុមហ៊ុនឯកជន " លេខ ៤៥០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់ក្រុមហ៊ុនឯកជនដែលបានពីការទូទាត់ ដោយអាណត្តិបើកប្រាក់ ការបង់ជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ ឬ បង្វែរពីប្រភពផ្សេងទៀត។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយសងទៅក្រុមហ៊ុន និងបង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលក្រុមហ៊ុនបានបង់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬបង្វែរមកពីប្រភពផ្សេងទៀត

- កត់ត្រាចំនួនទឹកប្រាក់ដែលក្រុមហ៊ុនបានទទួលពីការទូទាត់ដោយអាណត្តិបើកប្រាក់ និងពីគណនីប្រាក់បញ្ញើរបស់អង្គភាពផ្សេងទៀត

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ក្រុមហ៊ុនដែលកំពុងមាននៅរតនាគារ ហើយពុំទាន់ប្រើប្រាស់។

**ចំណាំ** :- គណនីនេះត្រូវតាមដានលម្អិតទៅតាមក្រុមហ៊ុននីមួយៗ។

- គណនីនេះត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។

**១២៥-គណនី ប្រាក់បញ្ញើរបស់អង្គការជាតិ “ លេខ ៤៥០២ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់អង្គការជាតិ ដែលបានផ្ញើនៅរតនាគារ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលអង្គការជាតិបានចំណាយជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ ឬ ដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ ឬ បង្វែរដែលអង្គការជាតិបានទទួល

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់អង្គការជាតិដែលកំពុងមាននៅរតនាគារ ហើយពុំទាន់បានប្រើប្រាស់។

**ចំណាំ** :- គណនីនេះត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គការជាតិនីមួយៗ។

**១២៦-គណនី ប្រាក់បញ្ញើរបស់អង្គការអន្តរជាតិ “ លេខ ៤៥០៣ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់អង្គការអន្តរជាតិ ដែលបានផ្ញើនៅរតនាគារ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលអង្គការអន្តរជាតិ បានចំណាយជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ ឬ ដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ ឬ បង្វែរដែលអង្គការអន្តរជាតិបានទទួល

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់អង្គការអន្តរជាតិដែលកំពុងមាននៅរតនាគារ ហើយពុំទាន់បានប្រើប្រាស់។

**ចំណាំ** :- គណនីនេះត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គការអន្តរជាតិនីមួយៗ។

**១២៧-គណនី ប្រាក់កក់ធានាការដេញថ្លៃ “ លេខ ៤៦០១ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អ្នកម៉ៅការ បានបង់សម្រាប់តម្កល់ធានាលើការដេញថ្លៃ។

**ការកត់ត្រា:**

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់កក់ធានាការដេញថ្លៃ ដែលបានចំណាយសងជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ

- កត់ត្រាចំនួនទឹកប្រាក់កក់ធានាការដេញថ្លៃ ដែលបានបង្វែរចូលថវិកា ឬ បង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលពីប្រាក់កក់ធានាការដេញថ្លៃ ដែលបានទទួលជាសាច់ប្រាក់ មូលប្បទានបត្រ ឬបង្វែរ

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់កក់ធានាការដេញថ្លៃ ដែលពុំទាន់បានសង។

**ចំណាំ** :- គណនីនេះត្រូវតាមដានលម្អិតទៅតាមអ្នកបង់ប្រាក់កក់ និងទៅតាមរូបិយប័ណ្ណនីមួយៗ។

- នៅពេលដកប្រាក់កក់ធានាការដេញថ្លៃវិញ អង្គភាពនីមួយៗត្រូវចេញលិខិតបញ្ជាក់មករតនាគារដើម្បីបើកផ្តល់ប្រាក់ជូនទៅអ្នកដេញថ្លៃវិញ។

**១២៨-គណនី ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា “ លេខ ៤៦០២ ” :**

គណនីនេះប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អ្នកម៉ៅការ បានបង់សម្រាប់តម្កល់ធានាលើការអនុវត្តកិច្ចសន្យាធានាគុណភាព និងធានាលើការផ្គត់ផ្គង់ សាងសង់ ដោយយោងតាមកិច្ចសន្យា។

**ការកត់ត្រា:**

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដែលបានចំណាយសងជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ឬដោយបង្វែរ

- កត់ត្រាចំនួនទឹកប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលបានបង្វែរចូលថវិកា ឬ បង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យាដែលបានទទួលជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ដែលពុំទាន់បានសង។

**ចំណាំ** : - គណនីនេះត្រូវតាមដានលម្អិតទៅតាមក្រសួង មន្ទីរ និងអង្គភាពជាអ្នកទទួលការផ្គត់ផ្គង់។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអ្នកបង់ប្រាក់ និងទៅតាមរូបិយប័ណ្ណនីមួយៗ។
- នៅពេលដកប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យាវិញ អង្គភាពនីមួយៗត្រូវចេញលិខិតបញ្ជាក់មករតនាគារ ដើម្បីបើកផ្តល់ប្រាក់ជូនទៅអ្នកបានបង់ប្រាក់កក់។

**១២៩-គណនី កម្រៃរួមរតនាគារ " លេខ ៤៧០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយប្រាក់កម្រៃសេវារតនាគារ ដែលបានមកពីសេវាផ្ទេរប្រាក់ពីគណនីប្រាក់បញ្ញើរបស់ឯកជន ពីគណនីប្រាក់បញ្ញើរបស់អង្គភាពស្វយ័ត ទៅគណនីមួយទៀត។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលបានបង្វែរចូលថវិការដ្ឋ

- កត់ត្រាចំនួនទឹកប្រាក់ដែលរតនាគាររាជធានី ខេត្ត បានផ្ទេរទៅរតនាគារកណ្តាល
- កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរទៅគណនីកម្រៃអត្ថប្រយោជន៍របស់រតនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលកម្រៃសេវារតនាគារ ដែលបានពីការបង្វែរពីគណនីផ្សេងទៀត ឬបង់ចូលគណនីចរន្តរបស់រតនាគារ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់កម្រៃរួមរបស់រតនាគារ ដែលពុំទាន់បានបែងចែក។

**ចំណាំ** : គណនីនេះត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**១៣០-គណនី កម្រៃអត្ថប្រយោជន៍រតនាគារ " លេខ ៤៧០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយប្រាក់កម្រៃជាអត្ថប្រយោជន៍របស់អគ្គនាយកដ្ឋានរតនាគារជាតិ ដែលបានមកពីការផ្ទេរពីគណនីកម្រៃរួមរតនាគារនៅថ្នាក់កណ្តាល និងបានពីការផ្ទេរពីរតនាគាររាជធានី ខេត្ត។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយជាសាច់ប្រាក់ ឬមូលប្បទានបត្រ ឬ បង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរពីគណនីកម្រៃរួមរតនាគារកណ្តាល និងផ្ទេរពីរតនាគាររាជធានី ខេត្ត (ចំណែកសល់ពីការបង់ចូលថវិកា)

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់កម្រៃជាអត្ថប្រយោជន៍របស់អគ្គនាយកដ្ឋានរតនាគារជាតិ ដែលពុំទាន់បានប្រើប្រាស់។

**១៣១-គណនី សាច់ប្រាក់បានទទួលពីរតនាគាររាជធានី ខេត្តរង់ចាំនិយ័តកម្ម " លេខ ៤៧០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនសាច់ប្រាក់ ដែលរតនាគារកណ្តាលបានទទួលពីរតនាគាររាជធានី ខេត្ត ផ្ទេរមកតាមរយៈធនាគារជាតិនៃកម្ពុជា ហើយរង់ចាំទូទាត់ជាមួយប្រកាសឥណពន្ធដែលរតនាគាររាជធានី ខេត្ត ត្រូវប្រគល់មករតនាគារកណ្តាលនៅពេលក្រោយ។ គណនីលេខ ៤៧០៣ ជាប្រភេទគណនីរង់ចាំ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនសាច់ប្រាក់ដែលបានទទួល ហើយបានជម្រះជាមួយប្រកាសឥណពន្ធរបស់រតនាគាររាជធានី ខេត្ត

ឥណទាន : កត់ត្រាចំនួនសាច់ប្រាក់ដែលបានទទួល ហើយពុំទាន់បានជម្រះជាមួយប្រកាសឥណពន្ធរបស់រតនាគាររាជធានី ខេត្ត

សមតុល្យ : ឥណទាយី បង្ហាញចំនួនសាច់ប្រាក់ដែលបានទទួលរង់ចាំការជម្រះជាមួយប្រកាសឥណពន្ធរបស់រតនាគាររាជធានី ខេត្ត។

**ចំណាំ** : គណនីនេះត្រូវតាមដានលម្អិតទៅតាមរតនាគាររាជធានី ខេត្ត ដែលបានផ្ទេរប្រាក់មក។

**១៣២-គណនី រដ្ឋទេយ្យករចំណូល " លេខ ៤៧០៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋទេយ្យករចំណូល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករចំណូលបានផ្ទេរចូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលរដ្ឋទេយ្យករបានបង់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ ចូលរតនាគារ ឬ គណនីរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងអង្គភាពប្រហាក់ប្រហែលនៅធនាគារ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករចំណូលពុំទាន់បានបង្វែរជាចំណូលថវិកា។

<u>ចំណាំ</u> : - គណនីនេះត្រូវមានគំរូហត្ថលេខារបស់រដ្ឋទេយ្យករចំណូល។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមរដ្ឋទេយ្យករចំណូលនីមួយៗ។

**១៣៣-គណនី ចំណូលបណ្តោះអាសន្ន “ លេខ ៤៧០៥ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធដែលបានទទួលជាសាច់ប្រាក់ ឬបង់ចូលគណនីចរន្តនៅធនាគារជាតិនៃកម្ពុជា នៅធនាគារពាណិជ្ជ និងសាខា ដោយរង់ចាំការរៀបចំសលាកបត្រផ្ទេរទៅជាចំណូលថវិកា ឬរង់ចាំបង្វែរចូលទៅមុខសញ្ញាផ្សេងទៀត។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង្វែរចូលថវិការដ្ឋ និងផ្ទេរទៅគណនីផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលជាបណ្តោះអាសន្នដែលបានទទួលជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬបង្វែរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលជាបណ្តោះអាសន្ន ហើយពុំទាន់មានសលាកបត្រ ផ្ទេរចូលថវិកា ឬ បែងចែកទៅមុខសញ្ញាផ្សេងទៀត។

<u>ចំណាំ</u> : - គណនីនេះត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។

- គណនីនេះត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**១៣៤-គណនី ចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ “ លេខ ៤៧០៦ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬ ចំនួនទឹកប្រាក់ដែលត្រូវបង្វែរទៅគណនីអកម្មផ្សេងទៀត។ គណនីនេះគឺជាប្រភេទគណនីរង់ចាំ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗនិងបង្វែរបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗនិងបង្វែររង់ចាំដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលរង់ចាំការបង្វែរនិងការដោះស្រាយ។

**១៣៥-អនុគណនី ទិសមភាពបេឡា ឥណទាយី “ លេខ ៤៧០៧១ ” :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់លម្អៀងលើសក្នុងបេឡារវាងបញ្ជីបេឡានិងសាច់ប្រាក់ជាក់ស្តែង ដោយយោងតាមបញ្ជីសារពើភ័ណ្ឌ និងប័ណ្ណចំណូលបេឡា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់លំអៀងលើសក្នុងបេឡាដែលបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់លំអៀងលើសក្នុងបេឡារង់ចាំដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់លំអៀងលើសក្នុងបេឡា ដែលពុំទាន់បានដោះស្រាយ។

**១៣៦-អនុគណនី ឥណទាយីផ្សេងៗ “ លេខ ៤៧០៧៨ ” :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវសងផ្សេងៗ ឬត្រូវផ្ទេរទៅគណនីអកម្មមួយទៀត ក្រៅពីបំណុលត្រូវសងទៅឱ្យអ្នកផ្គត់ផ្គង់ ក្រសួង មន្ទីរ អង្គភាព និងចំនួនទឹកប្រាក់ត្រូវដោះស្រាយ។ អនុគណនីលេខ ៤៧០៧៨ គឺជាប្រភេទគណនីចម្រុះ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗបានសង ឬ បានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗត្រូវសង ឬ ត្រូវដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ផ្សេងៗត្រូវសង ឬ ត្រូវដោះស្រាយ។

**១៣៧-អនុគណនី ពន្ធកាត់ទុកត្រូវសងផ្ទៃក្នុង ប្រព័ន្ធព័ត៌មានវិទ្យា “ លេខ ៤៧០៧៩ ” :**

អនុគណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ពន្ធ ដែលបានកាត់ទុកពីចំនួនទឹកប្រាក់ត្រូវសងទៅអ្នកផ្គត់ផ្គង់ អ្នកម៉ៅការតាមរយៈអាណត្តិបើកប្រាក់ ហើយប្រើនៅក្នុងកិច្ចបញ្ជិកាគណនេយ្យ តាមប្រព័ន្ធព័ត៌មានវិទ្យារបស់រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត។ អនុគណនី លេខ ៤៧០៧៩ ស្ថិតនៅក្នុងគណនី ឥណទាយីផ្សេងៗ។

ការកត់ត្រាខាងឥណពន្ធទន្ទឹមនឹងខាងឥណទាន ហើយត្រូវអសមតុល្យនៅពេលប្រតិបត្តិការត្រូវបានបញ្ចប់។

<u>ចំណាំ</u> : - អនុគណនីនេះគឺជាប្រភេទគណនីចម្លងក្នុងមុខងារគណនីត្រូវសង។

- អនុគណនីនេះមិនបង្ហាញនៅក្នុងតារាងតុល្យភាពគណនីទេ។

**១៣៨-គណនី ចម្លងផ្ទៃក្នុង ប្រព័ន្ធព័ត៌មានវិទ្យា “ លេខ ៤៧០៨ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវសងផ្សេងៗក្រៅពីគណនីត្រូវសងផ្សេងទៀតដែលបានកំណត់ក្នុងប្លង់គណនេយ្យនេះ និងកត់ត្រាដោយស្វ័យប្រវត្តិនូវចំនួនទឹកប្រាក់នៃប្រតិបត្តិការក្នុងមុខងារត្រូវទារ និងគ្រប់គ្រងសាច់ប្រាក់នៃប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការកត់ត្រាខាងឥណពន្ធទន្ទឹមនឹងខាងឥណទាន ហើយត្រូវអសមតុល្យនៅពេលប្រតិបត្តិការត្រូវបានបញ្ចប់។

<u>ចំណាំ</u> : - គណនីលេខ ៤៧០៨ ជាប្រភេទគណនីចម្លងក្នុងមុខងារគណនីត្រូវសង ត្រូវទារ និងគ្រប់គ្រងសាច់ប្រាក់។

- គណនីនេះមិនបង្ហាញនៅក្នុងតារាងតុល្យភាពគណនីទេ។

**១៣៩-គណនី ចម្លងកាត់ទុកផ្ទៃក្នុង ប្រព័ន្ធព័ត៌មានវិទ្យា “ លេខ ៤៧០៩ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធដែលបានកាត់ទុក ក្នុងមុខងារត្រូវសងនិងមុខងារត្រូវទារនៃប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងត្រូវផ្ទេរទៅគណនីចំណូលបណ្តោះអាសន្ន ពន្ធដារ ពន្ធគយ និងចំណូលមិនមែនសារពើពន្ធ ។

ការកត់ត្រាខាងឥណពន្ធទន្ទឹមនឹងខាងឥណទាន ហើយត្រូវអសមតុល្យនៅពេលប្រតិបត្តិការត្រូវបានបញ្ចប់។

<u>ចំណាំ</u> : - គណនីលេខ ៤៧០៩ ជាប្រភេទគណនីចម្លងក្នុងមុខងារគណនីត្រូវសង និងត្រូវទារ។

- គណនីនេះមិនបង្ហាញនៅក្នុងតារាងតុល្យភាពគណនីទេ។

**១៤០-គណនី ចំណូលសារពើពន្ធត្រូវប្រមូលបានកត់ត្រាទុកមុន “ លេខ ៤៨០១ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលពន្ធគយ និងពន្ធដារ ដែលត្រូវទារពីក្រុមហ៊ុន អាជីវករ។ គណនីលេខ ៤៨០១ កត់ត្រាបដិភាគជាមួយនឹងគណនីអ្នកជាប់ពន្ធ (លេខ ១៥០១) ដោយយោងតាមរបាយការណ៍ ឬ កិច្ចសន្យារបស់អង្គភាពពន្ធដារ និងអង្គភាពគយនិងរដ្ឋាករកម្ពុជា។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធគយនិងពន្ធដារ ដែលប្រមូលបាន ដោយបដិភាគនឹងគណនីអ្នកជាប់ពន្ធ

- កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធគយនិងពន្ធដារ ដែលបានជម្រះដោយបន្ធូរបន្ថយ ឬ លុបចោល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធគយនិងពន្ធដារ ដែលត្រូវប្រមូល ដោយបដិភាគនឹងគណនីអ្នកជាប់ពន្ធ

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលពន្ធគយនិងពន្ធដារ ដែលត្រូវប្រមូល។

<u>ចំណាំ</u> : - ការកត់ត្រាខាងឥណពន្ធគណនីលេខ ៤៨០១ ទន្ទឹមនឹងលេខនាកត់ត្រាចំណូលពិតប្រាកដ ដែលប្រមូលបាន (ឥណពន្ធ គណនីហិរញ្ញវត្ថុ និងឥណទាន គណនីចំណូលថវិកា)។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គភាពទទួលបន្ទុកបង់ចំណូល។

**១៤១-គណនី ចំណូលមិនមែនសារពើពន្ធត្រូវប្រមូលបានកត់ត្រាទុកមុន“ លេខ ៤៨០២ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធ ដែលត្រូវទារពីក្រុមហ៊ុន អាជីវករ។ គណនីលេខ ៤៨០២ កត់ត្រាបដិភាគជាមួយនឹងគណនី អតិថិជន (លេខ ១៥០២) ដោយយោងតាមរបាយការណ៍ ឬកិច្ចសន្យារបស់អង្គភាពគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលប្រមូលបាន ដោយបដិភាគនឹងគណនី អតិថិជន

- កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលបានជម្រះដោយបន្ធូរបន្ថយ ឬ លុបចោល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលត្រូវប្រមូល ដោយបដិភាគនឹងគណនីអតិថិជន

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធ ដែលត្រូវប្រមូល។

**ចំណាំ** : - ការកត់ត្រាខាងឥណពន្ធគណនីលេខ៤៨០២ ទន្ទឹមនឹងលេខនាកត់ត្រាចំណូលពិតប្រាកដ ដែលប្រមូលបាន (ឥណពន្ធ គណនីហិរញ្ញវត្ថុ និងឥណទាន គណនីចំណូលថវិកា)។

- គណនីនេះត្រូវតាមដានលម្អិតទៅតាមអង្គភាពគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

**១៤២-គណនី ប្រមូលផ្តុំប្រតិបត្តិការនៃការអនុវត្តមុខងារជាភ្នាក់ងារ " លេខ ៤៨០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាប្រមូលផ្តុំចំនួនទឹកប្រាក់ចំណាយ ដែលអង្គភាពអនុវត្តមុខងារបានទទួលសម្រាប់ការអនុវត្តមុខងារជាភ្នាក់ងារ។ គណនីលេខ ៤៨០៣ ប្រើនៅក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការបស់អង្គភាពដែលទទួលការអនុវត្តមុខងារជាភ្នាក់ងារ។ គណនីនេះគឺជាប្រភេទគណនីចម្លង។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់អនុវត្តមុខងារជាភ្នាក់ងារ ដោយបដិភាគជាមួយនឹងគណនីប្រាក់បញ្ញើនៅធនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវចំណាយសម្រាប់អនុវត្តមុខងារជាភ្នាក់ងារ ដោយបដិភាគជាមួយនឹងគណនីត្រូវសងនានា

**សមតុល្យ :** អសមតុល្យ។

**ចំណាំ** : - គណនីនេះត្រូវចែកជាអនុគណនី មុខងារជាភ្នាក់ងាររបស់ក្រសួង ស្ថាប័ន (លេខ ៤៨០៣១), មន្ទីរជំនាញ (លេខ ៤៨០៣២), រាជធានី ខេត្ត (លេខ ៤៨០៣៣), ក្រុង ស្រុក ខណ្ឌ (លេខ ៤៨០៣៤) និងអង្គភាពផ្សេងៗ (លេខ ៤៨០៣៨)។

- សរុបចលនាឥណាយិក និងចលនាឥណទាយីរបស់គណនីលេខ ៤៨០៣ ត្រូវស្មើនឹងសរុបតួលេខនៃគ្រប់គណនីចំណាយក្នុងតារាងតាមដានលម្អិតការអនុវត្តមុខងារជាភ្នាក់ងារ។

**១៤៣-គណនី ការខ្ចីក្នុងប្រទេស " លេខ ៥០០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ខ្ចីដែលក្រសួង ស្ថាប័ន ក្នុងនាមរាជរដ្ឋាភិបាល បានទទួលពីធនាគារ ឬ ស្ថាប័នឥណទានក្នុងប្រទេស។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានសង ឬបានកាត់បន្ថយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានទទួល

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់ខ្ចីដែលពុំទាន់បានសងទៅភាគីជាអ្នកឱ្យខ្ចី។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី ការខ្ចីពីធនាគារជាតិនៃកម្ពុជា (លេខ ៥០០១១), ធនាគារពាណិជ្ជ (លេខ ៥០០១២) និងការខ្ចីក្នុងប្រទេសផ្សេងៗ (លេខ ៥០០១៨)។

**១៤៤-គណនី ការខ្ចីក្រៅប្រទេស " លេខ ៥០០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ខ្ចីដែលក្រសួង ស្ថាប័ន ក្នុងនាមរាជរដ្ឋាភិបាល បានទទួលពីក្រៅប្រទេសពហុភាគី និងទ្វេភាគី។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានសង ឬ បានបន្ថយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានទទួល

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់ខ្ចីដែលពុំទាន់បានសងទៅភាគីជាអ្នកឱ្យខ្ចី។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី ការខ្ចីក្រៅប្រទេស ពហុភាគី (លេខ ៥០០២១) និងការខ្ចីក្រៅប្រទេស ទ្វេភាគី (លេខ ៥០០២២)។

**១៤៥-គណនី ការខ្ចីពីទីផ្សារហិរញ្ញវត្ថុ “ លេខ ៥០០៤ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាលបានខ្ចីពីទីផ្សារហិរញ្ញវត្ថុ តាមរូបភាពបោះផ្សាយសញ្ញាប័ណ្ណ ឬបណ្ណរដ្ឋាភិបាល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានសង ឬ បានបន្ថយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានទទួល

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់ខ្ចីដែលពុំទាន់បានសងទៅភាគីជាអ្នកឱ្យខ្ចី។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សញ្ញាប័ណ្ណ (លេខ ៥០០៤១) និងប័ណ្ណរដ្ឋាភិបាល (លេខ ៥០០៤២)។

**១៤៦-គណនី ប្រាក់តម្កល់ធានាសកម្មភាពអាជីវកម្ម “ លេខ ៥១០១ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការតម្កល់ធានាលើសកម្មភាពអាជីវកម្មរយៈពេលវែង របស់អាជីវករ ក្រុមហ៊ុន សហគ្រាស ដោយបង់ជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬបង្វែរចូលគណនីចរន្តរបស់រតនាគារ ឬចូលគណនីចរន្តរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពប្រហាក់ប្រហែលនៅធនាគារ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានសងទៅអាជីវករ ក្រុមហ៊ុន សហគ្រាសវិញ

- កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានផ្ទេរទៅជាចំណូលថវិកា ឬ បង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានទទួលពីអាជីវករ ក្រុមហ៊ុន សហគ្រាស

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់តម្កល់ធានាសកម្មភាពអាជីវកម្ម ដែលពុំទាន់បានសងទៅអាជីវករ ក្រុមហ៊ុន សហគ្រាសវិញ។

**<u>ចំណាំ</u>** : គណនីនេះត្រូវ តាមដានលម្អិតទៅតាមអ្នកបង់ប្រាក់ និងទៅតាមរូបិយប័ណ្ណនីមួយៗ។

**១៤៧-គណនី ប្រាក់តម្កល់គណបក្សនយោបាយ “ លេខ ៥១០២ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការតម្កល់ប្រាក់របស់គណបក្សនយោបាយ ដោយបង់ជាសាច់ប្រាក់ ជាមូលប្បទានបត្រ ឬបង្វែរចូលគណនីចរន្តរបស់រតនាគារនៅធនាគារ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តម្កល់ដែលបានសងទៅគណបក្សនយោបាយវិញ

- កត់ត្រាចំនួនទឹកប្រាក់តម្កល់ដែលបានផ្ទេរទៅជាចំណូលថវិកា ឬ បង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តម្កល់ដែលបានទទួលពីគណបក្សនយោបាយ

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់តម្កល់របស់គណបក្សនយោបាយ ដែលពុំទាន់បានសងទៅគណបក្សនយោបាយវិញ។

**<u>ចំណាំ</u>** : - គណនីនេះត្រូវតាមដានលម្អិតទៅតាមគណបក្សនយោបាយនីមួយៗ។

- រាល់ការបង់ប្រាក់ ឬ ដកប្រាក់ពីគណនីនេះ ត្រូវមានលិខិតសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**១៤៨-គណនី ប្រាក់តម្កល់ផ្សេងៗ “ លេខ ៥១០៨ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការតម្កល់ប្រាក់របស់អង្គភាពផ្សេងៗ ដោយបង់ជាសាច់ប្រាក់ ជាមូលប្បទានបត្រ ឬបង្វែរចូលគណនីចរន្តរបស់រតនាគារនៅធនាគារ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តម្កល់ផ្សេងៗដែលបានសងទៅអង្គភាពផ្សេងៗវិញ

- កត់ត្រាចំនួនទឹកប្រាក់តម្កល់ផ្សេងៗដែលបានផ្ទេរទៅជាចំណូលថវិកា ឬ បង្វែរទៅមុខសញ្ញាផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តម្កល់ដែលបានទទួលពីអង្គភាពផ្សេងៗ

**សមតុល្យ :** ឥណទាយី បង្ហាញចំនួនទឹកប្រាក់តម្កល់របស់គណបក្សនយោបាយ ដែលពុំទាន់បានសងអង្គភាពវិញ។

**<u>ចំណាំ</u>** : គណនីនេះត្រូវ តាមដានលម្អិតទៅតាមអង្គភាពផ្សេងៗ និងទៅតាមរូបិយប័ណ្ណនីមួយៗ។

**១៤៩-គណនី សម្ភារផ្គត់ផ្គង់ថែទាំ " លេខ ៦០០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារផ្គត់ផ្គង់ថែទាំ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ (លេខ ៦០០១១), សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ (លេខ ៦០០១២), សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ (លេខ ៦០០១៣), សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍ (លេខ ៦០០១៤), ប្រេងឥន្ធនៈ និងប្រេងរំអិល (លេខ ៦០០១៥) និង សម្ភារផ្គត់ផ្គង់ថែទាំផ្សេងៗ (លេខ ៦០០១៨)។

**១៥០-គណនី សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល " លេខ ៦០០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញ សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សម្ភារការិយាល័យ (លេខ ៦០០២១), សៀវភៅមើល និងឯកសារ (លេខ ៦០០២២), ការបោះពុម្ព (លេខ ៦០០២៣) និងសម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ (លេខ ៦០០២៨)។

**១៥១-គណនី ស្បៀងអាហារ និងផលិតផលកសិកម្ម " លេខ ៦០០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញស្បៀងអាហារ និងផលិតផលកសិកម្ម។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ស្បៀង (លេខ ៦០០៣១), ចំណីសត្វ (លេខ ៦០០៣២), ពូជ និងកូនរុក្ខជាតិ (លេខ ៦០០៣៣), ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និងជី (លេខ ៦០០៣៤), ពូជសត្វ (លេខ ៦០០៣៥), ឱសថ និង វត្ថុធាតុសម្រាប់បសុពេទ្យ (លេខ ៦០០៣៦), ស្បៀងសម្រាប់រដ្ឋបាល (លេខ ៦០០៣៧) និងស្បៀងអាហារ និង ផលិតផលកសិកម្មផ្សេងៗ (លេខ ៦០០៣៨)។

**១៥២-គណនី សំលៀកបំពាក់ និងការតុបតែង " លេខ ៦០០៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសំលៀកបំពាក់ និងការតុបតែងលម្អ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ឯកសណ្ឋាន (លេខ ៦០០៤១), សំលៀកបំពាក់ការពារសុវត្ថិភាព (លេខ ៦០០៤២), មេដាយ (គ្រឿងឥស្សរិយយស) (លេខ ៦០០៤៣) និងសំលៀកបំពាក់ និងការតុបតែងផ្សេងៗ (លេខ ៦០០៤៨)។

**១៥៣-គណនី សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ " លេខ ៦០០៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណទាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា (លេខ ៦០០៥១), សង្ហារឹម (លេខ ៦០០៥២), សម្ភារប្រើប្រាស់ (លេខ ៦០០៥៣), សម្ភារ និងឧបករណ៍ដឹកជញ្ជូន (លេខ ៦០០៥៤), សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា (លេខ ៦០០៥៥) និង សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារផ្សេងៗ (លេខ ៦០០៥៨)។

**១៥៤-គណនី ថាមពលនិងទឹក "លេខ ៦០០៦" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ ការប្រើប្រាស់ថាមពលនិងទឹក។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណទាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជា អនុគណនី សម្រាប់ អគ្គិសនី (លេខ ៦០០៦១), ទឹក (លេខ ៦០០៦២) និងថាមពលផ្សេងៗ (លេខ ៦០០៦៨)។

**១៥៥-គណនី សម្ភារបរិក្ខារថែទាំសុខភាព "លេខ ៦០០៧" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារបរិក្ខារថែទាំសុខភាព។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណទាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី បំពង់ហ្គាសនិងអុកស៊ីសែន (លេខ ៦០០៧១), សម្ភារបរិក្ខារពេទ្យ (លេខ ៦០០៧២) និងសម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ (លេខ ៦០០៧៨)។

**១៥៦-គណនី សម្ភារផ្គត់ផ្គង់ផ្សេងៗ "លេខ ៦០៩៨" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារផ្គត់ផ្គង់ផ្សេងៗទៀត ដែលពុំបានរៀបរាប់ខាងលើក្នុងគណនីនៃជំពូក៦០។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណទាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**១៥៧-គណនី បម្រែបម្រួលសន្និធិ "លេខ ៦០៩៩" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃបម្រែបម្រួលសន្និធិ ដែលបានបញ្ចូល និងបានបញ្ចេញ។

**ការកត់ត្រា:**

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិ ដែលបានបញ្ចេញជាប្រចាំ

- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដើមគ្រា ដែលបានធ្វើមោឃកម្ម
- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិ ដែលបានកើនឡើង ហើយបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិ ដែលបានបញ្ចូលជាប្រចាំ
- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិដើមគ្រា ដែលបានបញ្ចូលនៅចុងគ្រា
- កត់ត្រាចំនួនទឹកប្រាក់នៃសន្និធិ ដែលបានថយចុះ ហើយបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : - ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់នៃសន្និធិដែលបានថយចុះ ពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ
- ឥណទាន បង្ហាញចំនួនទឹកប្រាក់នៃសន្និធិដែលបានកើនឡើងពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : - គណនីបម្រែបម្រួលសន្និធិមានការកត់ត្រាបដិភាគជាមួយគណនីសន្និធិ និងគណនីលទ្ធផលនៃការិយបរិច្ឆេទ។
- គណនីបម្រែបម្រួលសន្និធិត្រូវស្មូន្យសមតុល្យនៅពេលចុងឆ្នាំ ក្រោយពីបានផ្ទេរសមតុល្យទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។
- គណនីនេះត្រូវបែកជាអនុគណនី បម្រែបម្រួលសន្និធិសម្ភារផ្គត់ផ្គង់ថែទាំ (លេខ ៦០៩៩១), បម្រែបម្រួលសន្និធិសម្ភារផ្គត់ផ្គង់រដ្ឋបាល (លេខ ៦០៩៩២), បម្រែបម្រួលសន្និធិស្បៀងអាហារនិងផលិតផលកសិកម្ម (លេខ ៦០៩៩៣), បម្រែបម្រួលសន្និធិសំលៀកបំពាក់និងការតុបតែង (លេខ ៦០៩៩៤), បម្រែបម្រួលសន្និធិសម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ (លេខ ៦០៩៩៥), បម្រែបម្រួលសន្និធិសម្ភារបរិក្ខារថែទាំសុខភាព (លេខ ៦០៩៩៧) និងបម្រែបម្រួលសន្និធិសម្ភារផ្គត់ផ្គង់ផ្សេងៗ (លេខ ៦០៩៩៨)។

**១៥៨-គណនី កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស " លេខ ៦១០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ជូនទៅសហគ្រាស ក្រុមហ៊ុន ឬអាជីវករ ដែលបានផ្តល់សេវាកម្ម។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីនេះត្រូវបែកជាអនុគណនី សេវាអនាម័យ (លេខ ៦១០១១), សេវារដ្ឋបាល (លេខ ៦១០១២) និងសេវាផ្សេងៗ (លេខ ៦១០១៨)។

**១៥៩-គណនី ការជួលមធ្យោបាយដឹកជញ្ជូន " លេខ ៦១០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ថ្លៃឈ្នួលមធ្យោបាយដឹកជញ្ជូន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីនេះត្រូវបែកជាអនុគណនី ការជួលមធ្យោបាយដឹកជញ្ជូន (លេខ ៦១០២១) និងការជួលមធ្យោបាយដឹកជញ្ជូនផ្សេងៗ (លេខ ៦១០២៨)។

**១៦០-គណនី ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) ក្នុងនិងក្រៅប្រទេស " លេខ ៦១០៣ " :**

គណនីនេះប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ថ្លៃឈ្នួលទីតាំងស្នាក់ការរដ្ឋបាលនៅក្នុងប្រទេសនិងក្រៅប្រទេស។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីនេះត្រូវបែកជាអនុគណនី ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) ក្នុងប្រទេស (លេខ ៦១០៣១), ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) ក្រៅប្រទេស (លេខ ៦១០៣២) និងថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) ផ្សេងៗ (លេខ ៦១០៣៨)។

**១៦១-គណនី សោហ៊ុយបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស " លេខ ៦១០៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស (លេខ ៦១០៤១) និង សោហ៊ុយបណ្តុះបណ្តាលផ្សេងៗ ក្នុងនិងក្រៅប្រទេស (លេខ ៦១០៤៨)។

**១៦២-គណនី ការថែទាំនិងជួសជុល " លេខ ៦១០៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការថែទាំនិងជួសជុល ដែលអនុវត្តដោយក្រុមហ៊ុន ឬសហគ្រាស ជានីតិបុគ្គល រូបវន្តបុគ្គល និងអង្គភាពរដ្ឋ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែនទេសាទ (លេខ ៦១០៥១), ការថែទាំជួសជុលអគារផ្សេងៗ និងប្រាសាទ (លេខ ៦១០៥២), ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ (លេខ ៦១០៥៣), ការថែទាំបណ្តាញផ្សេងៗ (លេខ ៦១០៥៤), ការថែទាំប្រព័ន្ធធារាសាស្ត្រ (លេខ ៦១០៥៥), ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន (លេខ ៦១០៥៦), ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស (លេខ ៦១០៥៧) និងការថែទាំនិងជួសជុលផ្សេងៗ (លេខ ៦១០៥៨)។

**១៦៣-គណនី សោហ៊ុយធានារ៉ាប់រង " លេខ ៦១០៦ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបង់សោហ៊ុយធានារ៉ាប់រងផ្សេងៗ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយធានារ៉ាប់រងលើអគារ (លេខ ៦១០៦១), សោហ៊ុយធានារ៉ាប់រងលើយានយន្ត (លេខ ៦១០៦២), សោហ៊ុយធានារ៉ាប់រងលើសុខភាព (លេខ ៦១០៦៣) និងសោហ៊ុយធានារ៉ាប់រងផ្សេងៗទៀត (លេខ ៦១០៦៨)។

**១៦៤-គណនី សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា សោហ៊ុយនៃការប្រើប្រាស់សិទ្ធិនិងសំណងផ្សេងៗ " លេខ ៦១០៧" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិនិងសំណងផ្សេងៗ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយសិក្សាពិសោធន៍ (លេខ ៦១០៧១), សោហ៊ុយនៃការប្រើប្រាស់សេវា (លេខ ៦១០៧២), សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ (លេខ ៦១០៧៣), សំណងផ្នែកស៊ីវិល (លេខ ៦១០៧៤) សោហ៊ុយនិងសំណងផ្សេងៗ (លេខ ៦១០៧៨)។

**១៦៥-គណនី សោហ៊ុយដឹកជញ្ជូន “ លេខ ៦១០៨ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើសោហ៊ុយដឹកជញ្ជូនសម្ភារនិងទំនិញដែលផ្តល់ដោយសហគ្រាស និង ក្រុមហ៊ុនជានីតិបុគ្គលនិងជារូបវន្តបុគ្គល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវបែកជាអនុគណនី សម្ភារ និងទំនិញ (លេខ ៦១០៨១) និងសោហ៊ុយដឹកជញ្ជូនផ្សេងៗ (លេខ ៦១០៨៨)។

**១៦៦-គណនី បុគ្គលិកខាងក្រៅ “ លេខ ៦១០៩ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ប្រាក់លាភការរបស់បុគ្គលិកក្រៅពីបុគ្គលិកដែលមិនមែនជា មន្ត្រីរាជការ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវបែកជាអនុគណនី ភ្នាក់ងារជាតិជាប់កិច្ចសន្យា (លេខ ៦១០៩១), ភ្នាក់ងារបរទេសជាប់កិច្ចសន្យា (លេខ ៦១០៩២), បុគ្គលិកសម្ព័ហភាពសាធារណៈផ្សេងៗ (លេខ ៦១០៩៣), ប្រាក់វិភាជន៍សង្គមសម្រាប់បុគ្គលិកខាងក្រៅ (លេខ ៦១០៩៤) និងបុគ្គលិកខាងក្រៅផ្សេងៗ (លេខ ៦១០៩៨)។

**១៦៧-គណនី ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ “ លេខ ៦១១០ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវបែកជាអនុគណនី សោហ៊ុយទទួលភ្ញៀវជាតិ (លេខ ៦១១០១), សោហ៊ុយទទួលភ្ញៀវបរទេស (លេខ ៦១១០២), ប្រជុំ សិក្ខាសាលា និងសន្និសីទ (លេខ ៦១១០៣), ចំណាយរៀបចំពិធីបុណ្យ (លេខ ៦១១០៤), ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស (លេខ ៦១១០៥), ចំណាយសម្រាប់ការតាំងពិព័រណ៍ នៅក្នុងនិងក្រៅប្រទេស (លេខ ៦១១០៦), ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ (លេខ ៦១១០៧) និងទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយផ្សេងៗ (លេខ ៦១១០៨)។

**១៦៨-គណនី សារព័ត៌មាន និងឯកសារ “ លេខ ៦១១១ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់ថ្លៃជាវសារព័ត៌មាននិងទិញឯកសារ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវបែកជាអនុគណនី ចំណាយលើការជាវសារព័ត៌មាន (លេខ ៦១១១១), ចំណាយលើការជាវទស្សនាវដ្តី (លេខ ៦១១១២), ចំណាយលើការជាវសៀវភៅរាជកិច្ច (លេខ ៦១១១៣) និងចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ (លេខ ៦១១១៨)។

**១៦៩-គណនី សោហ៊ុយបេសកកម្មក្នុងប្រទេស " លេខ ៦១១២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់សោហ៊ុយធ្វើដំណើរ ប្រាក់បេសកកម្ម និងសោហ៊ុយស្នាក់នៅក្នុងប្រទេសរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយដឹកជញ្ជូន (លេខ ៦១១២១), សោហ៊ុយបេសកកម្ម (លេខ ៦១១២២), សោហ៊ុយស្នាក់នៅ (លេខ ៦១១២៣) និងសោហ៊ុយក្នុងប្រទេសផ្សេងៗ (លេខ ៦១១២៨)។

**១៧០-គណនី សោហ៊ុយបេសកកម្មក្រៅប្រទេស " លេខ ៦១១៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់សោហ៊ុយធ្វើដំណើរ ប្រាក់បេសកកម្ម និងសោហ៊ុយស្នាក់នៅក្រៅប្រទេសរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណាយិកបង្ហាញពីចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយដឹកជញ្ជូន (លេខ ៦១១៣១), សោហ៊ុយបេសកកម្ម (លេខ ៦១១៣២), សោហ៊ុយស្នាក់នៅ (លេខ ៦១១៣៣) និងសោហ៊ុយក្រៅប្រទេសផ្សេងៗ (លេខ ៦១១៣៨)។

**១៧១-គណនី សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ " លេខ ៦១១៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទូទាត់សេវាទូរគមនាគមន៍ ទូរស័ព្ទ តេឡិច និងទូរសារប្រៃសណីយ៍។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយប្រៃសណីយ៍ (លេខ ៦១១៤១), សោហ៊ុយទូរគមនាគមន៍ (លេខ ៦១១៤២) និងសោហ៊ុយទូរគមនាគមន៍ផ្សេងៗ (លេខ ៦១១៤៨)។

**១៧២-គណនី សោហ៊ុយធនាគារ " លេខ ៦១១៥ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើសេវាផ្សេងៗរបស់ធនាគារ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សោហ៊ុយធនាគារ (លេខ ៦១១៥១)។

**១៧៣-គណនី សំណងកិច្ចសន្យា " លេខ ៦១១៦ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការសងទៅក្រុមហ៊ុនជានីតិបុគ្គល ឬរូបវន្តបុគ្គល ដែលជាថ្នូរនៃការរំលត់កិច្ចសន្យាមុនកាលកំណត់។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ផ្លូវថ្នល់ ផ្លូវទឹក (លេខ ៦១១៦១), ផារាសាស្ត្រ (លេខ ៦១១៦២), អាយស្ម័យយាន (លេខ ៦១១៦៣), អាកាសយានដ្ឋាន (លេខ ៦១១៦៤), ទូរគមនាគមន៍ (លេខ ៦១១៦៥), អគ្គិសនី (លេខ ៦១១៦៦), បណ្តាញបង្ហូរទឹក និងអនាម័យ (លេខ ៦១១៦៧) និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (លេខ ៦១១៦៨)។

**១៧៤-គណនី សេវាកម្មផ្សេងៗទៀត “ លេខ ៦១៩៨ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើសោហ៊ុយនិងសេវាកម្មផ្សេងៗ ដែលពុំបានរៀបរាប់ខាងលើក្នុងជំពូក៦១។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី សេវាកម្មផ្សេងៗទៀត (លេខ ៦១៩៨១)។

**១៧៥-គណនី អត្ថប្រយោជន៍សន្តិសុខសង្គម “ លេខ ៦២០១ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើអត្ថប្រយោជន៍សន្តិសុខសង្គម ដែលជាអត្ថប្រយោជន៍ហិរញ្ញវត្ថុទទួលបានពេលចូលនិវត្តន៍។ ចំនួនទឹកប្រាក់នេះ បានបង់ចូលប្រព័ន្ធសន្តិសុខសង្គមក្នុងអំឡុងពេលកម្មករធ្វើការ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី អត្ថប្រយោជន៍សន្តិសុខសង្គម (លេខ ៦២០១១)។

**១៧៦-គណនី ជំនួយសង្គមដល់ប្រជាពលរដ្ឋ “ លេខ ៦២០២ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការជួយដល់ប្រជាពលរដ្ឋទាំងផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ជំនួយដល់ប្រជាជនសម្រាកពេទ្យ និងចំណាយដំណើរការរបស់មណ្ឌលថែទាំសុខភាព (លេខ ៦២០២១), ឱសថ (លេខ ៦២០២២), អាហារនិងសម្ភារ (ស្បៀង) (លេខ ៦២០២៣), ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ (លេខ ៦២០២៤), អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស (លេខ ៦២០២៥), អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្រៅប្រទេស (លេខ ៦២០២៦), សំណងខូចខាតដោយសារឧបទ្ទវហេតុសាធារណៈ (លេខ ៦២០២៧) និងជំនួយសង្គមផ្សេងៗទៀត (លេខ ៦២០២៨)។

**១៧៧-គណនី ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គមនិងវប្បធម៌ “ លេខ ៦២០៣ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការផ្តល់ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ទាំងផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពេក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកជាអនុគណនី ឧបត្ថម្ភសហគមន៍ និងរក្សាសណ្ដាប់ធ្នាប់ សន្តិសុខសង្គម (លេខ ៦២០៣១), ឧបត្ថម្ភមណ្ឌលកុមារកំព្រា (លេខ ៦២០៣២), ឧបត្ថម្ភដំណើរលំហែ និងសិក្សា (លេខ ៦២០៣៣), ឧបត្ថម្ភកាកបាទក្រហម (លេខ ៦២០៣៤), ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌ (លេខ ៦២០៣៥), ឧបត្ថម្ភ មណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍ (លេខ ៦២០៣៦), ចំណាយសង្គមកិច្ចរបស់ព្រះមហាក្សត្រ (លេខ ៦២០៣៧) និងឧបត្ថម្ភដល់អង្គភាពផ្សេងៗទៀត (លេខ ៦២០៣៨)។

**១៧៨-គណនី ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ “ លេខ ៦២០៤ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការឧបត្ថម្ភដល់អង្គការមូលដ្ឋាននិងគាំទ្រកម្មវិធីផ្សេងៗ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពេក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកជាអនុគណនី ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ (លេខ ៦២០៤១)។

**១៧៩-គណនី ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច “ លេខ ៦២០៥ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើកិច្ចការអន្តរាគមន៍ ផ្នែកសេដ្ឋកិច្ច។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពេក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីនេះចែកជាអនុគណនី ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច (លេខ ៦២០៥១)។

**១៨០-គណនី ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌ “ លេខ ៦២០៦ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការជម្រុញកិច្ចការសិក្សា អប់រំ ដូចជា÷ ការគាំទ្រដល់គណៈកម្មការប្រឡង ឬក្រុមការងារដែលមិនមែនជាមន្ត្រីរាជការពីក្រសួងមុខងារសាធារណៈ និងចំណាយផ្សេងៗទៀត ដែលមានផលប្រយោជន៍លើកម្ពស់ការងារពាក់ព័ន្ធផ្នែកសង្គមកិច្ចនិងវប្បធម៌។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពេក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកជាអនុគណនី ចំណាយលើការប្រឡង-ប្រឡងប្រជែង (លេខ ៦២០៦១) និង ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌ផ្សេងៗទៀត (លេខ ៦២០៦៨)។

**១៨១-គណនី អត្ថប្រយោជន៍សង្គមផ្សេងទៀត “ លេខ ៦២៩៨ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ដែលពុំបានរៀបរាប់ខាងលើនៅក្នុងជំពូក៦២។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី អត្ថប្រយោជន៍សង្គមផ្សេងទៀត (លេខ ៦២៩៨១)។

**១៨២-គណនី លតាប័ត្រ " លេខ ៦៣០១ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបង់ពន្ធយានយន្តប្រចាំឆ្នាំ ដែលជាកម្មសិទ្ធរបស់អង្គភាព។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី លតាប័ត្រ (លេខ ៦៣០១១)។

**១៨៣-គណនី បន្ទុកពន្ធគយលើការនាំចូលទំនិញ និងសម្ភារ " លេខ ៦៣០២ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើបន្ទុកពន្ធគយលើការនាំចូលទំនិញនិងសម្ភារ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី បន្ទុកពន្ធគយលើការនាំចូលទំនិញ និងសម្ភារ (លេខ ៦៣០២១), បន្ទុកពន្ធគយលើការនាំចូលទំនិញ និងសម្ភារកសិកម្ម (ជាបន្ទុករបស់រដ្ឋ) (លេខ ៦៣០២២), បន្ទុកពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) (លេខ ៦៣០២៣) និងផ្សេងៗ (លេខ ៦៣០២៨)។

**១៨៤-គណនី បន្ទុកពន្ធប្រថាប់ត្រា " លេខ ៦៣០៣ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើបន្ទុកពន្ធប្រថាប់ត្រា ដើម្បីទទួលបានកម្មសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់អចលនទ្រព្យ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី បន្ទុកពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធ ឬសិទ្ធិកាន់កាន់អចលនទ្រព្យ (លេខ ៦៣០៣១), ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងវង្វង់ញាតិ និងការអនុគ្រោះពន្ធជាបន្ទុករបស់រដ្ឋ (លេខ ៦៣០៣២) និងផ្សេងៗ (លេខ ៦៣០៣៨)។

**១៨៥-គណនី បន្ទុកពន្ធលើផលទុននៃដីធ្លី ផ្ទះសម្បែង " លេខ ៦៣០៤ " :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើបន្ទុកពន្ធលើផលទុននៃដីធ្លី ផ្ទះសម្បែង។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី បន្ទុកលើផលទុនដីធ្លី ផ្ទះសម្បែង (លេខ ៦៣០៤១)។

**១៨៦-គណនី អាករលើតម្លៃបន្ថែមលើទំនិញ និងសេវាជាបន្ទុករបស់រដ្ឋ “ លេខ ៦៣០៥ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការលើកលែងអាករតម្លៃបន្ថែមលើសេវាដែលការចំណាយនេះជាបន្ទុករបស់រដ្ឋ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី អាករលើតម្លៃបន្ថែមលើទំនិញជាបន្ទុករបស់រដ្ឋ (លេខ ៦៣០៥១), អាករលើតម្លៃបន្ថែមលើសេវាជាបន្ទុករបស់រដ្ឋ (លេខ ៦៣០៥២) និងអាករលើតម្លៃបន្ថែមផ្សេងៗជាបន្ទុករបស់រដ្ឋ (លេខ ៦៣០៥៨)។

**១៨៧-គណនី ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ និងពន្ធលើប្រាក់ចំណូល “លេខ ៦៣០៦”:**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើបន្ទុកពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ និងពន្ធលើប្រាក់ចំណូល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទជាបន្ទុករបស់រដ្ឋ (លេខ ៦៣០៦១), ពន្ធលើអចលនទ្រព្យជាបន្ទុករបស់រដ្ឋ (លេខ ៦៣០៦២), ពន្ធលើប្រាក់ចំណូលនីតិបុគ្គលជាបន្ទុករបស់រដ្ឋ (លេខ ៦៣០៦៣) និងផ្សេងៗ (លេខ ៦៣០៦៨)។

**១៨៨-គណនី ពន្ធនិងអាករផ្សេងៗ “ លេខ ៦៣៩៨ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើពន្ធនិងអាករផ្សេងៗ ដែលពុំបានរៀបរាប់ខាងលើក្នុងជំពូក៦៣។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ពន្ធនិងអាករផ្សេងៗ (លេខ ៦៣៩៨១)។

**១៨៩-គណនី លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ “ លេខ ៦៤០១ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើលាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ** : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**<u>ចំណាំ</u>** : គណនីនេះត្រូវចែកជាអនុគណនី ខុទ្ទកាល័យព្រះបរមរាជវាំង (លេខ ៦៤០១១), ប្រាក់បំណាច់ ប្រធាន អនុប្រធាន និងសមាជិកស្ថាប័នកំពូល (លេខ ៦៤០១២), ប្រាក់បំណាច់ នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី (លេខ ៦៤០១៣), ប្រាក់បំណាច់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ (លេខ ៦៤០១៤), ប្រាក់បំណាច់អភិបាល (លេខ ៦៤០១៥), លាភការទីប្រឹក្សា (លេខ ៦៤០១៦), លាភការបេសកជន (លេខ ៦៤០១៧) និងលាភការអ្នកជំនួយការ (លេខ ៦៤០១៨)។

**១៩០-គណនី លាភការ និងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ “ លេខ ៦៤០២ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើលាភការ និងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវចែកជាអនុគណនី បៀវត្សមូលដ្ឋាន (លេខ ៦៤០២១), ប្រាក់បំណាច់មុខងារ (លេខ ៦៤០២២), ប្រាក់បំណាច់ម៉ោងបន្ថែម (លេខ ៦៤០២៣), ប្រាក់កម្រៃគុណសល្យ (លេខ ៦៤០២៤), ប្រាក់បំប៉នជីវភាពពិសេស (លេខ ៦៤០២៥), ប្រាក់បំណាច់តំបន់ (លេខ ៦៤០២៦), ប្រាក់បំណាច់ទទួលខុសត្រូវ (លេខ ៦៤០២៧) និងប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព (លេខ ៦៤០២៨)។

### ១៩១-គណនី ប្រាក់បំណាច់ផ្សេងៗ “ លេខ ៦៤០៣ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើប្រាក់បំណាច់ផ្សេងៗទៀត។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវចែកទៅជាអនុគណនី រង្វាន់ (លេខ ៦៤០៣៣), ប្រាក់បំណាច់បុគ្គលិកអង្គភាពផ្សេងៗ (លេខ ៦៤០៣៤), ប្រាក់បំណាច់គ្រូបង្គោលអង្គភាពផ្សេងៗ (លេខ ៦៤០៣៥), ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់អង្គភាពដទៃទៀត (លេខ ៦៤០៣៧) និងប្រាក់បំណាច់ផ្សេងៗ (លេខ ៦៤០៣៨)។

### ១៩២-គណនី លាភការ និងប្រាក់បំណាច់ បុគ្គលិកមិនមែនក្របខ័ណ្ឌ “ លេខ ៦៤០៤ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើលាភការ និងប្រាក់បំណាច់ជូនបុគ្គលិកមិនមែនក្របខ័ណ្ឌ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវចែកជាអនុគណនី បៀវត្សមូលដ្ឋាន បុគ្គលិកជាប់កិច្ចសន្យា (លេខ ៦៤០៤១), លាភការផ្សេងៗទៀតបុគ្គលិកជាប់កិច្ចសន្យា (លេខ ៦៤០៤២) និងលាភការផ្សេងៗ (លេខ ៦៤០៤៨)។

### ១៩៣-គណនី ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ “ លេខ ៦៤០៥ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : *គណនីនេះត្រូវចែកជាអនុគណនី មន្ត្រីមានជម្ងឺ (លេខ ៦៤០៥១), ម្ដាយសម្រាលកូន (លេខ ៦៤០៥២), មរណភាព* (លេខ ៦៤០៥៣), ឧបត្ថម្ភនិវត្តជន (លេខ ៦៤០៥៤), ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ (លេខ ៦៤០៥៥), គ្រោះថ្នាក់ក្នុងការងារនិងទព្វលភាព (លេខ ៦៤០៥៦) និងប្រាក់វិភាជន៍សង្គមផ្សេងៗទៀតសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ (លេខ ៦៤០៥៨)។

### ១៩៤-គណនី ប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ “ លេខ ៦៤០៦ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្ញូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី ឧបត្ថម្ភកូនមានអាយុចាប់ពី២០ឆ្នាំចុះ (លេខ ៦៤០៦១), ប្រាក់បំណាច់អ្នកក្នុងបន្ទុក (លេខ ៦៤០៦៣), ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ (លេខ ៦៤០៦៤) និងប្រាក់វិភាជន៍សង្គមផ្សេងៗទៀតសម្រាប់គ្រួសារមន្ត្រីរាជការ (លេខ ៦៤០៦៨)។

**១៩៥-គណនី លាភការ និងប្រាក់បំណាច់នៃអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ "លេខ ៦៤០៧" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើលាភការ និងប្រាក់បំណាច់នៃអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្ញូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះចែកជាអនុគណនី ប្រាក់បំណាច់អភិបាល (រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ) (លេខ ៦៤០៧១), ប្រាក់បំណាច់អភិបាលរង (រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ) (លេខ ៦៤០៧២), ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សា (រាជធានី ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់) (លេខ ៦៤០៧៣), ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ (លេខ ៦៤០៧៤), លាភការទីប្រឹក្សា (លេខ ៦៤០៧៥), លាភការបេសកជន (លេខ ៦៤០៧៦), លាភការអ្នកជំនួយការ (លេខ ៦៤០៧៧) និងប្រាក់បំណាច់ផ្សេងៗទៀត (លេខ ៦៤០៧៨)។

**១៩៦-គណនី បន្ទុកបុគ្គលិកផ្សេងៗទៀត "លេខ ៦៤៩៨" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើបន្ទុកបុគ្គលិកផ្សេងៗទៀត ដែលពុំបានរៀបរាប់ខាងលើក្នុងជំពូក៦៤។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្ញូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី បន្ទុកបុគ្គលិកផ្សេងៗទៀត (លេខ ៦៤៩៨១)។

**១៩៧-គណនី ឧបត្ថម្ភធនរវាងរដ្ឋបាលសាធារណៈ "លេខ ៦៥០១" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការផ្តល់ឧបត្ថម្ភធនរវាងរដ្ឋបាលសាធារណៈទាំងនោះ។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

**សមតុល្យ :** ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្ញូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ** : គណនីនេះត្រូវចែកជាអនុគណនី ឧបត្ថម្ភធនដល់រាជធានី-ខេត្ត (លេខ ៦៥០១១), ឧបត្ថម្ភធនដល់ក្រុង-ស្រុក-ខណ្ឌ (លេខ ៦៥០១២), ឧបត្ថម្ភធនដល់ឃុំ-សង្កាត់ (លេខ ៦៥០១៣), ឧបត្ថម្ភធនដល់ក្រសួង ស្ថាប័ន (លេខ ៦៥០១៤) និងឧបត្ថម្ភធនផ្សេងៗ (លេខ ៦៥០១៨)។

**១៩៨-គណនី ឧបត្ថម្ភធនដល់អង្គភាពសាធារណៈ "លេខ ៦៥០២" :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការឧបត្ថម្ភធនដល់អង្គភាពសាធារណៈនានា។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្រមូលបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

__ចំណាំ__ : គណនីនេះត្រូវចែកជាអនុគណនី ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសេដ្ឋកិច្ច (លេខ ៦៥០២១), ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម (លេខ ៦៥០២២), ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈអប់រំ និងកីឡា (លេខ ៦៥០២៣), ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម (លេខ ៦៥០២៤), ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈវប្បធម៌ (លេខ ៦៥០២៥), ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈរដ្ឋបាល (លេខ ៦៥០២៦), ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈច្បាប់ (លេខ ៦៥០២៧) និងឧបត្ថម្ភធនដល់អង្គភាពផ្សេងៗ (លេខ ៦៥០២៨)។

**១៩៩-គណនី ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល “ លេខ ៦៥០៣ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការផ្តល់ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្រមូលបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

__ចំណាំ__ : គណនីនេះត្រូវចែកជាអនុគណនី ឧបត្ថម្ភធនជាហិរញ្ញវត្ថុដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល (លេខ ៦៥០៣១) និងឧបត្ថម្ភធនមិនមែនហិរញ្ញវត្ថុដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល (លេខ ៦៥០៣២)។

**២០០-គណនី ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈ “ លេខ ៦៥០៤ ” :**

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការផ្តល់ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈ ដើម្បីទ្រទ្រង់សកម្មភាពអាជីវកម្ម ផលិតកម្ម។

**ការកត់ត្រា:**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្រមូលបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

__ចំណាំ__ : គណនីនេះត្រូវចែកជាអនុគណនី ឧបត្ថម្ភធនដល់ក្រុមហ៊ុនរដ្ឋ ដែលមានលក្ខណៈហិរញ្ញវត្ថុ (លេខ ៦៥០៤១), ឧបត្ថម្ភធនដល់ក្រុមហ៊ុនចម្រុះ ដែលមានលក្ខណៈហិរញ្ញវត្ថុ (លេខ ៦៥០៤២), ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច (លេខ ៦៥០៤៣), ឧបត្ថម្ភធនដល់ក្រុមហ៊ុនរដ្ឋ ដែលមានលក្ខណៈមិនមែនហិរញ្ញវត្ថុ (លេខ ៦៥០៤៤) និងឧបត្ថម្ភធនដល់ក្រុមហ៊ុនចម្រុះ ដែលមានលក្ខណៈមិនមែនហិរញ្ញវត្ថុ (លេខ ៦៥០៤៥)។

**២០១-គណនី ឧបត្ថម្ភធនដល់សហគ្រាសឯកជន “ លេខ ៦៥០៥ ” :**

